លឹម ផល្គុន និង សែន ពិសិដ្ឋ

បរិញ្ញាបត្រផ្នែកគណិតវិទ្យា

គណិតវិទ្យាជុំវិញពិភពលោក

សម្រាប់ សិស្សពូកែផ្នែកគណិតវិទ្យា

ត្រៀមប្រឡងអាហារូបករណ៍

ភាគ១០



$f(b)-f(a)=f'(c)(b-a)$

Problem and Solution

គណិតវិទ្យាជុំវិញពិភពលោក

រៀបរៀងដោយ ៖

លឹម ផល្លុន និង សែន ពិសិដ្ឋ

ភាគទី ១០

គណៈកម្មការនិពន្ធ និង រៀបរៀង

លឹម ផល្គុន និង សែន ពិសិដ្ឋ

គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

លោក លឹម ឆុន

លោក នន់ សុខណា

លោក ព្រឹម សុនិត្យ

លោក និត្យ ម៉េង

លោក អ៊ឹង សំណាង

លោកស្រី នុយ រីណា

លោក ផល ប៊ុនឆាយ

គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិគ្គសិរ

ការីកុំព្យូទ័រ

កញ្ញា លី គុណ្ណាភា

លោក អ៊ឹង សំណាង

អារម្ភកថា

សៀវភៅគណិតវិទ្យាជុំវិញពិភពលោកភាគទី១០ ដែលអ្នកសិក្សាកំពុងកាន់នៅក្នុងដៃនេះ ចែកចេញជាបីផ្នែកដែលផ្នែកទី១ ជាកម្រងលំហាត់ជ្រើសរើស ផ្នែកទី២ ជាផ្នែកដំណោះស្រាយ និង ផ្នែកទី៣ ជាលំហាត់អនុវត្តន៍ ។ រាល់បប្រធានលំហាត់នីមួយៗនៅក្នុងសៀវភៅនេះ យើងខ្ញុំបានជ្រើសរើសយកតែ លំហាត់ណាដែលមានលក្ខណៈពិបាក មកធ្វើដំណោះស្រាយគំរូយ៉ាងក្បោះក្បាយបំផុត ។

គោលបំណងនៃការរៀបរៀងចងក្រងគឺដើម្បីទុកជាឯកសារជំនួយសម្រាប់អ្នកសិក្សាក្នុងគ្រប់មជ្ឈដ្ឋាន និង ម្យ៉ាងទៀតដើម្បីចូលរួមលើកស្ទួយវិស័យគណិតវិទ្យាក្នុងប្រទេសកម្ពុជាយើងឱ្យកាន់តែរីកចម្រើនឆាប់រហស័ស្របតាមសម័យវិទ្យាសាស្ត្រទំនើប ។

សៀវភៅនេះមិនល្អហួសគេហួសឯងនោះទេ ។ កំហុសឆ្គងដោយអចេតនាប្រាកដជាមានទាំងបច្ចេកទេស និង អក្ខរាវិរុទ្ធ ។ ហេតុនេះយើងខ្ញុំជាអ្នកនិពន្ធ រងចាំជានិច្ចនូវមតិរិះគន់បែបស្ថាបនាពីអ្នកសិក្សាគ្រប់មជ្ឈដ្ឋានដោយក្តីរីករាយដើម្បីកែលំអសៀវនេះឱ្យកាន់តែមានសុក្រិត្យភាពប្រសើរឡើងថែមទៀត ។

ជាទីបញ្ចប់ ខ្ញុំបាទអ្នកនិពន្ធសូមគោរពជូនពរអ្នកសិក្សាទាំងអស់មានសុខភាពល្អមានប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យជានិច្ចក្នុងការសិក្សា ។

បាត់ដំបង ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១១

អ្នកនិពន្ធ និង ស្រាវជ្រាវ **លឹម ផល្គុន**
Tel : 017 768 246
Email: lim_phalkun@ymail.com
Website: www.mathtoday.wordpress.com

ជំពូកទី១

កម្រងលំហាត់ជ្រើសរើស

ជំពូកទី១

កម្រងលំហាត់ជ្រើសរើស

1. គេឱ្យចំនួនពិត $x_1, x_2, y_1, y_2, z_1, z_2$ ផ្ទៀងផ្ទាត់ $x_1 > 0, x_2 > 0$
   $x_1y_1 - z_1^2 > 0$ និង $x_2y_2 - z_2^2 > 0$ ។
   ចូរស្រាយថា :
   $$\frac{8}{(x_1+x_2)(y_1+y_2)-(z_1+z_2)^2} \le \frac{1}{x_1y_1 - z_1^2} + \frac{1}{x_2y_2 - z_2^2}$$
   (IMO 1969)

2. គេតាង I និង O រៀងគ្នាជាផ្ចិតរង្វង់ចារឹកក្នុងនិងផ្ចិតរង្វង់ចារឹកក្រៅនៃត្រីកោណ គេឱ្យត្រីកោណ ABC មួយ ។
   ចូរស្រាយថា $\angle OIA = 90^o$ លុះត្រាតែ AB, BC, CA ជាស្វ៊ីតនព្វន្ត ។

3. គេឱ្យ n ជាចំនួនគត់វិជ្ជមានដោយដឹងថា $2 + 2\sqrt{28n^2 + 1}$ ជាចំនួនគត់ ។
   ចូរស្រាយថា $2 + 2\sqrt{28n^2 + 1}$ ជាការេប្រាកដនៃចំនួនគត់មួយ ។

4. គេយក x ជាចំនួនពិត ដោយដឹងថា $0 < x < \frac{\pi}{2}$ ។
   ចូរបង្ហាញថា $\cos^2(x)\cot(x) + \sin^2(x)\tan(x) \ge 1$

   (Baltic Way 2010)

5. គេឱ្យត្រីកោណ $\mathbf{ABC}$ មួយមានជ្រុង $\mathbf{a,b,c}$ ។ តាង $\mathbf{r}$ និង $\mathbf{R}$ រៀងគ្នាជាកាំរង្វង់ចារឹកក្នុង និង កាំរង្វង់ចារឹកក្រៅនៃ $\Delta\ \mathbf{ABC}$ ។

ក. ចូរស្រាយថា $\mathbf{a\cos A + bosB + c\cos C = \frac{2pr}{R}}$

$$\mathbf{\frac{\cos A}{a} + \frac{\cos B}{b} + \frac{\cos C}{c} = \frac{a^2+b^2+c^2}{2abc}}$$

$$\mathbf{\cos A + \cos B + \cos C = 1 + \frac{r}{R}}$$

ដែល $\mathbf{p = \frac{a+b+c}{2}}$ ជាកន្លះបរិមាត្រនៃត្រីកោណ ។

ខ. ចូរទាញបញ្ជាក់ថា $\mathbf{a^2+b^2+c^2 \geq 4(R+r)^2}$ ($\mathbf{A,B,C}$ ជាមុំស្រួច) ។

6. គេឱ្យ $\mathbf{f}$ ជាអនុគមន៍កំណត់ពីសំណុំ $\mathbf{IR}$ ទៅសំណុំ $\mathbf{IR_+^*}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $\mathbf{f(x+y) = f(x).f(y)}$ ចំពោះគ្រប់ $\mathbf{x,y \in IR}$ និង $\mathbf{f'(0) = \lambda}$

ចូរកំណត់រកអនុគមន៍ $\mathbf{y = f(x)}$ ។

7. ស៊ីត $\mathbf{\{a_n\}}$ កំណត់ដោយ $\mathbf{a_1 = \frac{21}{16}}$ និងចំពោះ $\mathbf{n \geq 2 : 2a_n - 3a_{n-1} = \frac{3}{2^{n+1}}}$

គេយក $\mathbf{m}$ ជាចំនួនគត់មួយដែល $\mathbf{m \geq 2}$ ។ ចូរបង្ហាញថាចំពោះ $\mathbf{n \leq m}$

យើងបាន $\mathbf{\left(a_n + \frac{3}{2^{n+3}}\right)^{\frac{1}{m}} \left(m - \left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right) < \frac{m^2-1}{m-n+1}}$?

(China National Olympiad 2005)

៨. គេឱ្យ a,b,c ជាចំនួនពិតវិជ្ជមានដែល $a+b+c=3$ ។

ចូរស្រាយបញ្ជាក់វិសមភាព $\frac{a^2}{a+b^2}+\frac{b^2}{b+c^2}+\frac{c^2}{c+a^2}\ge\frac{3}{2}$

(Croatia Team Selection Tests 2011)

៩.គេឱ្យ a,b,c ជាជ្រុងរបស់ត្រីកោណមួយ ។ ចូរស្រាយថា :

$$\frac{(c+a-b)^4}{a(a+b-c)}+\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)}\ge ab+bc+ca$$

(Greece National Olympiad 2007)

10. គេឱ្យ f ជាអនុគមន៍កំណត់ពី $(0,+\infty)$ ទៅ IR ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ

$f(x)+f(y)=f(xy)$ គ្រប់ $x>0,y>0$ និង $f'(1)=\lambda$ ។

ចូរកំណត់រកអនុគមន៍ $y=f(x)$ ។

11. គេកំណត់ចំនួន $a_0,a_1,a_2,....,a_n$ ដូចខាងក្រោម :

$$a_0=\frac{1}{2};a_{k+1}=a_k+\frac{{a_k}^2}{n}\quad(\ n>1,k=0,1,2,....,n-1\ )$$

ចូរបង្ហាញថា $1-\frac{1}{n}<a_n<1$ ។

(IMO Longlists 1980)

12. គេឱ្យ f ជាអនុគមន៍ជាប់ និង មានដេរីវេលើ IR ដែលចំពោះគ្រប់ $x,y\in IR$

គេមានទំនាក់ទំនង $f(x+y)=\frac{f(x)+f(y)}{1+f(x)f(y)}$ និង $f(x)\neq\pm1$ គ្រប់ x ។

ចូរកំណត់អនុគមន៍ $y=f(x)$ ។

13. ចូរបង្ហាញថា :

$$\log_a bc + \log_b ca + \log_c ab \ge 4(\log_{ab} c + \log_{bc} a + \log_{ca} b)$$

ចំពោះគ្រប់ a, b, c ធំជាងមួយ ។

(Malaysia National Olympiad 2010)

14. គេឱ្យរង្វង់ផ្ចិត **O** កាំ **r** និងត្រីកោណ **ABC** ប្រែប្រួលចារឹកក្រៅរង្វង់ ។ បន្ទាត់កាត់តាម **O** កាត់ជ្រុង **AB** និង **AC** រៀងគ្នាត្រង់ **M** និង **N** ។ កំណត់ទីតាំងចំណុច **A** និងអង្កត់ **[MN]** ដើម្បីឱ្យផ្ទៃក្រឡាត្រីកោណ **AMN** មានតម្លៃតូចបំផុត ?

(ប្រឡងសិស្សពូកែប្រចាំរាជធានីភ្នំពេញ ២០០៩)

15. គេតាង α, β, γ ជារង្វាស់មុំក្នុងត្រីកោណ **ABC** មួយដែលមានបរិមាត្រ **2p** និងកាំរង្វង់ចារឹកក្រៅ **R** ។

a/ ចូរស្រាយបញ្ជាក់ថា :

$$\cot^2\alpha + \cot^2\beta + \cot^2\gamma \ge 3\left(9.\frac{R^2}{p^2} - 1\right)$$

b/ តើពេលណាទើបគេបានសមភាព ?

(Morocco National Olympiad 2011)

16. គេឱ្យម៉ាទ្រីស $A=\begin{bmatrix}3&1&1\\1&3&1\\1&1&3\end{bmatrix}$ និង $I=\begin{bmatrix}1&0&0\\0&1&0\\0&0&1\end{bmatrix}$

បង្ហាញថាមានស្ទីតចំនួនពិតពីរ (u_n) និង (v_n) ដែលផ្ទៀងផ្ទាត់ :

$\forall n\in IN:\ A^n=u_n.I+v_n.A$ ដែលគេនឹងបញ្ជាក់តួទូទៅ u_n

និង v_n ជាអនុគមន៍នៃ n ។

17. គេឱ្យ f ជាអនុគមន៍ជាប់ និង មានដេរីវេលើ IR ដែលចំពោះគ្រប់ $x,y\in IR$

គេមានទំនាក់ទំនង $f(\frac{x+y}{2})=\sqrt{f(x)f(y)}$ និង $f(x)>0$ ។

ចូរកំណត់អនុគមន៍ $y=f(x)$ ។

18. គេឱ្យចតុកោណប៉ោង $ABCD$ មួយមានជ្រុង$AB=a\,,BC=b\,,$

$CD=c$ និង $DA=d$ ។

P ជាចំនុចមួយនៅក្នុងចតុកោណហើយ $K\,,L\,,M\,,N$ ជាចំណោលកែង

នៃចំនុច P លើជ្រុង $[AB],[BC],[CD],[DA]$ រៀងគ្នា ។

គេដឹងថា $\frac{PK}{AB}=\frac{PL}{BC}=\frac{PM}{CD}=\frac{PN}{DA}=h$ ។

ក. ចូរស្រាយថា $h=\frac{2S}{a^2+b^2+c^2+d^2}$ ដែល S ជាផ្ទៃក្រឡានៃ

ចតុកោណ $ABCD$ ។

ខ.ចូរបង្ហាញថា $h\le\frac{1}{2}$

19. គេឱ្យចតុកោណប៉ោង $\mathbf{ABCD}$ មួយមានជ្រុង $\mathbf{AB=a}$, $\mathbf{BC=b}$

$\mathbf{CD=c}$ និង $\mathbf{DA=d}$ ។ $\mathbf{O}$ ជាចំនុចមួយនៅក្នុងចតុកោណនេះដែល

$\angle\mathbf{OAB}=\angle\mathbf{OBC}=\angle\mathbf{OCD}=\angle\mathbf{ODA}=\theta$ ($\mathbf{0<\theta<90^o}$)

ក. ចូរស្រាយថា $\mathbf{\tan\theta=\dfrac{4S}{a^2+b^2+c^2+d^2}}$

ដែល $\mathbf{S}$ ជាផ្ទៃក្រឡានៃចតុកោណ $\mathbf{ABCD}$ ។

ខ. កំនត់ θ ដោយដឹងថា $\mathbf{\tan\theta}$ មានតម្លៃធំបំផុត ។

20. ចំពោះគ្រប់ $\mathbf{x;y\geq 0}$ ចូរស្រាយបញ្ជាក់វិសមភាព :

$$\mathbf{\sqrt{x^2-x+1}\sqrt{y^2-y+1}+\sqrt{x^2+x+1}\sqrt{y^2+y+1}\geq 2(x+y)}$$

(Kazakhstan NMO 2010**)**

21. គេឱ្យ $\mathbf{a,b,c}$ ជាចំនួនពិតវិជ្ជមាន ។ ចូរស្រាយបញ្ជាក់ថា :

$$\mathbf{\frac{(2a+b+c)^2}{2a^2+(b+c)^2}+\frac{(2b+c+a)^2}{2b^2+(c+a)^2}+\frac{(2c+a+b)^2}{2c^2+(a+b)^2}\leq 8}$$

(USAMO 2003)

22. ចូរបង្ហាញថា $$\mathbf{\frac{1}{\frac{1}{a}+\frac{1}{b}}+\frac{1}{\frac{1}{c}+\frac{1}{d}}\leq\frac{1}{\frac{1}{a+c}+\frac{1}{b+d}}}$$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $\mathbf{a,b,c,d}$ ។ (*វៀតណាម* 1962)

23. ចូរបង្ហាញថា $\frac{1}{(x-y)^2}+\frac{1}{(y-z)^2}+\frac{1}{(z-x)^2}\geq\frac{4}{xy+yz+zx}$

ចំពោះគ្រប់ចំនួនពិតមិនអវិជ្ជមានខុសគ្នា x,y,z ។

(វៀតណាម 2008)

24. ចូរកំណត់តួទូទៅនៃស្វ៊ីតដែលកំណត់ដោយ :

$x_0=3, x_1=4$ និង $x_{n+1}=x_{n-1}^2-nx_n$ ចំពោះគ្រប់ $n\in\mathbb{N}$ ។

25. ចូរកំណត់គ្រប់ចំនួនពិត x បើគេដឹងថា $\frac{8^x+27^x}{12^x+18^x}=\frac{7}{6}$ ។

26. ចូរគណនាផលបូក :

$$S_n=\frac{3}{1!+2!+3!}+\frac{4}{2!+3!+4!}+...+\frac{n+2}{n!+(n+1)!+(n+2)!}$$

27. (China 1983)

គេឱ្យ f ជាអនុគមន៍កំណត់លើចន្លោះ $[0,1]$ ដោយដឹងថា :

$f(0)=f(1)=1$ និង $|f(a)-f(b)|<|a-b|$

ចំពោះគ្រប់ $a\neq b$ ក្នុងចន្លោះ $[0,1]$ ។

ចូរបង្ហាញថា $|f(a)-f(b)|<\frac{1}{2}$ ។

28. (AIME 1988)

ចូរកំណត់គូនៃចំនួនគត់ (a,b) ដោយដឹងថា $ax^{17}+bx^{16}+1$

ចែកដាច់នឹង x^2-x-1 ។

29. ដោះស្រាយក្នុងសំណុំចំនួនពិតនៃសមីការ :

$$x^3 - 3x = \sqrt{x+2}$$ ។

30. (Korean Mathematics Competition 2000)

ចូរកំណត់គ្រប់ចំនួនពិត x ដែលផ្ទៀងផ្ទាត់សមីការ :

$$2^x + 3^x - 4^x + 6^x - 9^x = 1$$

31. (China 1992)

ចូរបង្ហាញថា $16 < \sum_{k=1}^{80} \frac{1}{\sqrt{k}} < 17$

32. គេឱ្យ z_1, z_2, z_3 ជាចំនួនកុំផ្លិចដែល $\begin{cases} z_1 + z_2 + z_2 = 2 \\ {z_1}^2 + {z_2}^2 + {z_3}^2 = 3 \\ z_1 z_2 z_3 = 4 \end{cases}$

ចូរគណនាតម្លៃ $S = \frac{1}{z_1 z_2 + z_3 - 1} + \frac{1}{z_2 z_3 + z_1 - 1} + \frac{1}{z_3 z_1 + z_2 - 1}$

33. គេឱ្យ x, y, z ជាបីចំនួនពិតវិជ្ជមានដែល $x^4 + y^4 + z^4 = 1$ ។

ចូរកំណត់តម្លៃតូចបំផុតនៃ $\frac{x^3}{1-x^8} + \frac{y^3}{1-y^8} + \frac{z^3}{1-z^8}$ ។

34. (Iran 1996)

គេឱ្យបីចំនួនពិតមិនអវិជ្ជមាន a, b, c និងមិនសូន្យព្រមគ្នាពីរ ។

ចូរស្រាយបញ្ជាក់ថា :

$$(ab + bc + ca)\left[\frac{1}{(a+b)^2} + \frac{1}{(b+c)^2} + \frac{1}{(c+a)^2}\right] \geq \frac{9}{4}$$

35. គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមាន ។

ចូរស្រាយថា $a^3+b^3+c^3-3abc \geq 2\left(\frac{b+c}{2}-a\right)^3$ ។

36. គេឱ្យត្រីកោណ ABC មួយមានជ្រុង $BC=a$, $CA=b$, $AB=c$

ហើយមុំក្នុង A,B,C ជាមុំស្រួចឬមុំកែង ។

តាង S ជាផ្ទៃក្រឡានៃ $\Delta\ ABC$

ចូរស្រាយបញ្ជាក់ថា $\frac{1}{a^4}+\frac{1}{b^4}+\frac{1}{c^4} \geq \frac{9}{16S^2}$ ។

37. (Turkey 2007)

គេឱ្យបីចំនួនពិតវិជ្ជមាន a,b,c ដែល $a+b+c=1$ ។

ចូរស្រាយបញ្ជាក់ថា :

$$\frac{1}{ab+2c^2+2c}+\frac{1}{bc+2a^2+2a}+\frac{1}{ca+2b^2+2b} \geq \frac{1}{ab+bc+ca}$$

38. គេឱ្យ a,b,c ជាបីចំនួនពិតវិជ្ជមាន ។

ចូរស្រាយបញ្ជាក់ថា :

$$\frac{a^2}{\sqrt{2a^2+ab+b^2}}+\frac{b^2}{\sqrt{2b^2+bc+c^2}}+\frac{c^2}{\sqrt{2c^2+ca+a^2}} \geq \frac{a+b+c}{2}$$

39. គេឱ្យ a,b,c ជាបីចំនួនពិតខុសគ្នា ។

ចូរស្រាយថា $\frac{a^2}{(b-c)^2}+\frac{b^2}{(c-a)^2}+\frac{c^2}{(a-b)^2} \geq 2$ ។

40. ចូរស្រាយបញ្ជាក់វិសមភាព :

$$\sqrt{a^2+(1-b)^2}+\sqrt{b^2+(1-c)^2}+\sqrt{c^2+(1-a)^2}\geq\frac{3\sqrt{2}}{2}$$

ចំពោះគ្រប់ចំនួនពិត a,b,c ។

41. គេឱ្យត្រីកោណ ABC មួយកែងត្រង់ C ។ D និង E ជាចំណុចពីរជ្រើសរើស នៅលើអ៊ីប៉ូតេនូស ដែល$BC=BD$ និង $AC=AE$ ។

F និង G ជាចំណោលកែងនៃ D និង E លើជ្រុង AC និង BC រៀងគ្នា ។

ចូរស្រាយបញ្ជាក់ថា $DE=DF+EG$ ។

42. គេយក D ជាចំនុចមួយនៃជ្រុង BC របស់ត្រីកោណ ABC ហើយ E និង F ជាចំណោលកែងនៃ B និង C លើ AD ។

បើ R ជាចំនុចកណ្ដាលនៃ BC នោះស្រាយថា $RE=RF$

43. គេឱ្យការេ $ABCD$ មួយ ។ E ជាប្រសព្វរវាងអង្កត់ទ្រូងទាំងពីរ ហើយ N ជាចំនុចមួយស្ថិតលើ AE ។

ចូរស្រាយថា $AB^2-BN^2=AN.NC$ និង $AN^2+NC^2=2BN^2$

44. គេឱ្យ ABC ជាត្រីកោណមួយហើយ D ជាជើងនៃកម្ពស់គូសពីកំពូល A ។ យក E និង F ស្ថិតនៅលើបន្ទាត់កាត់តាមD ដោយដឹងថា AE កែងនឹង BE ហើយ AF កែងនឹង CF ដែល E និង F ខុសពី D ។

យក M និង N ជាចំណុចកណ្ដាលនៃអង្កត់ BC និង EF រៀងគ្នា ។

ចូរស្រាយថា AN កែងនឹង NM ?

45. រកអនុគមន៍ $f : IR \mapsto IR$ ដែលផ្ទៀងផ្ទាត់ :

$$\forall \mathbf{x,y} \in \mathbf{IR}:\ \mathbf{f((x-y)^2) = x^2 - 2yf(x) + \left(f(y)\right)^2}$$

46. ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $\mathbf{a,b,c}$ ចូរស្រាយបញ្ជាក់ថា :

$$\sqrt[3]{(a+b)(b+c)(c+a)} \geq \sqrt[6]{\frac{(a^2+b^2)(b^2+c^2)(c^2+a^2)}{8}} + \sqrt[3]{abc}$$

47.(**Greece National Olympiad 2011**)

គេឱ្យ a,b,c ជាចំនួនពិតវិជ្ជមានដែលមានផលបូកស្មើ 6 ។

ចូរកំណត់តម្លៃអតិបរមានៃ :

$$\mathbf{S = \sqrt[3]{a^2+2bc} + \sqrt[3]{b^2+2ca} + \sqrt[3]{c^2+2ab}}$$

48.(USAMO 1989)

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $\mathbf{n}$ គេឱ្យ :

$$\mathbf{S_n = 1 + \frac{1}{2} + \frac{1}{3} + ... + \frac{1}{n}}$$

$$\mathbf{T_n = S_1 + S_2 + S_3 + ... + S_n}$$

$$\mathbf{U_n = \frac{T_1}{2} + \frac{T_2}{3} + \frac{T_3}{4} + ... + \frac{T_n}{n+1}}$$

ចូរកំណត់ដោយធ្វើដំណោះស្រាយ នូវចំនួនគត់ $\mathbf{0 < a,b,c,d < 1000\,000}$

ដោយដឹងថា $\mathbf{T_{1988} = aS_{1989} - b}$ និង $\mathbf{U_{1988} = cS_{1989} - d}$ ។

49.(Japan Mathematical Olympiad Finals 2010)

គេឱ្យ x,y,z ជាចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា :

$$\frac{1+yz+zx}{(1+x+y)^2}+\frac{1+zx+xy}{(1+y+z)^2}+\frac{1+xy+yz}{(1+z+x)^2}\geq 1$$ ។

50. (**China Team Selection Test 2002**)

គេឱ្យស្វ៊ីត $a_1=1,\ a_2=5$ និង $a_{n+1}=\dfrac{a_n a_{n-1}}{\sqrt{a_n^{\ 2}+a_{n-1}^2+1}}\ \forall n\geq 2$

ចូរកំណត់តួទូទៅនៃស្វ៊ីត $\{a_n\}$ ជាអនុគមន៍នៃ n ។

51. (**China Team Selection Test 2006**)

គេឱ្យ $x_1,x_2,....,x_n$ ជាចំនួនពិតវិជ្ជមានដែល $\sum\limits_{i=1}^{n} x_i=1$ ។

ចូរស្រាយថា :

$$\left(\sum_{i=1}^{n}\sqrt{x_i}\right)\left(\sum_{i=1}^{n}\frac{1}{\sqrt{1+x_i}}\right)\leq\frac{n^2}{\sqrt{n+1}}$$ ។

52.(**China Team Selection Test 2005**)

គេឱ្យ a,b,c ជាបីចំនួនពិតមិនអវិជ្ជមាន ដែល $ab+bc+ca=\dfrac{1}{3}$ ។

ចូរបង្ហាញថា $\dfrac{1}{a^2-bc+1}+\dfrac{1}{b^2-ca+1}+\dfrac{1}{c^2-ab+1}\leq 3$ ។

ជំពូកទី២

ផ្នែកដំណោះស្រាយ

ជំពូកទី២

ផ្នែកដំណោះស្រាយ

លំហាត់ទី១

គេឱ្យចំនួនពិត $\mathbf{x_1\,,x_2\,,y_1\,,y_2\,,z_1\,,z_2}$ ផ្ទៀងផ្ទាត់ $\mathbf{x_1>0\,,x_2>0}$

$\mathbf{x_1y_1-z_1^{\;2}>0}$ និង $\mathbf{x_2y_2-z_2^{\;2}>0}$ ។

ចូរស្រាយថា :

$$\frac{8}{(x_1+x_2)(y_1+y_2)-(z_1+z_2)^2}\le\frac{1}{x_1y_1-z_1^{\;2}}+\frac{1}{x_2y_2-z_2^{\;2}}$$

(IMO 1969)

ដំណោះស្រាយ

ស្រាយថា :

$$\frac{8}{(x_1+x_2)(y_1+y_2)-(z_1+z_2)^2}\le\frac{1}{x_1y_1-z_1^{\;2}}+\frac{1}{x_2y_2-z_2^{\;2}}\quad(*)$$

តាង $\mathbf{a=x_1y_1-z_1^{\;2}>0\;;\;b=x_2y_2-z_2^{\;2}>0}$

និង $\mathbf{c=(x_1+x_2)(y_1+y_2)-(z_1+z_2)^2}$

ដោយ $\mathbf{x_1>0}$ និង $\mathbf{x_2>0}$ នោះ $\mathbf{y_1=\dfrac{a+z_1^{\;2}}{x_1}>0}$ និង $\mathbf{y_2>0}$

គេមាន :

$$c=(x_1y_1-z_1^2)+(x_2y_2-z_2^2)+x_1y_2+x_2y_1-2z_1z_2$$

$$c=a+b+x_1y_2+x_2y_1-2z_1z_2$$

ដោយ $a=x_1y_1-z_1^2$ នោះ $x_1=\dfrac{a+z_1^2}{y_1}$

និង $b=x_2y_2-z_2^2$ នោះ $x_2=\dfrac{b+z_2^2}{y_2}$

គេបាន $c=a+b+y_2(\dfrac{a+z_1^2}{y_1})+y_1(\dfrac{b+z_2^2}{y_2})-2z_1z_2$

$$=a+b+\frac{y_2}{y_1}a+\frac{y_1}{y_2}b+\frac{y_2}{y_1}z_1^2-2z_1z_2+\frac{y_1}{y_2}z_2^2$$

$$=a+b+\frac{y_2}{y_1}a+\frac{y_1}{y_2}b+\left(\sqrt{\frac{y_2}{y_1}}\,z_1-\sqrt{\frac{y_1}{y_2}}\,z_2\right)^2$$

ដោយ $\left(\sqrt{\dfrac{y_2}{y_1}}z_1-\sqrt{\dfrac{y_1}{y_2}}z_2\right)^2\geq 0$ នោះគេទាញបាន :

$c\geq a+b+\dfrac{y_2}{y_1}a+\dfrac{y_1}{y_2}b$ ដោយ $\dfrac{y_2}{y_1}a+\dfrac{y_1}{y_2}b\geq 2\sqrt{ab}$

នោះ $c\geq a+b+2\sqrt{ab}=(\sqrt{a}+\sqrt{b})^2$ **(1)**

យើងឧបមាថាវិសមភាព **(*)** ពិតពោលគឺ $\dfrac{8}{c}\leq\dfrac{1}{a}+\dfrac{1}{b}$ ពិត

គេបាន $c\geq\dfrac{8ab}{a+b}$ ដោយ $c\geq(\sqrt{a}+\sqrt{b})^2$ （តាមវិសមភាព **(1)** ）

យើងនឹងស្រាយថា $(\sqrt{a}+\sqrt{b})^2 \geq \frac{8ab}{a+b}$

សមមូល $(a+b)(\sqrt{a}+\sqrt{b})^2 \geq 8ab$

តាមវិសមភាព $AM-GM$ គេមាន :

$a+b \geq 2\sqrt{ab}$ ហើយ $(\sqrt{a}+\sqrt{b})^2 \geq 4\sqrt{ab}$

នោះ $(a+b)(\sqrt{a}+\sqrt{b}) \geq 8ab$ ពិត

ដូចនេះ

$$\frac{8}{(x_1+x_2)(y_1+y_2)-(z_1+z_2)^2} \leq \frac{1}{x_1y_1-{z_1}^2}+\frac{1}{x_2y_2-{z_2}^2}$$

វិសមភាពនេះក្លាយសមភាពលុះត្រាតែ :

$z_1\sqrt{\frac{y_2}{y_1}} = z_2\sqrt{\frac{y_1}{y_2}}$ ឬ $z_1y_2 = z_2y_1$ និង $\frac{y_2}{y_1}a = \frac{y_1}{y_2}b$ ។

លំហាត់ទី២

គេតាង **I** និង **O** រៀងគ្នាជាផ្ចិតរង្វង់ចារឹកក្នុងនិងផ្ចិតរង្វង់ចារឹកក្រៅ

នៃត្រីកោណ គេឱ្យត្រីកោណ **ABC** មួយ ។

ចូរស្រាយថា $\angle OIA = 90^o$ លុះត្រាតែ AB, BC, CA ជាស្វ៊ីតនព្វន្ត ។

ដំណោះស្រាយ

ស្រាយថា $\angle OIA = 90^o$ លុះត្រាតែ AB, BC, CA ជាស្វ៊ីតនព្វន្ត



តាង $BC = a$, $AC = b$, $AB = c$ និង $p = \frac{a+b+c}{2}$

ហើយ **r** និង **R** ជាកាំរង្វង់ចារឹកក្នុង និង ចារឹកក្រៅនៃត្រីកោណ **ABC** ។

យក **H** ជាចំណោលនៃ **I** លើ **[AC]** នោះគេបាន :

$IH = r$ និង $AH = p - a$ ។

-សន្មតថា $\angle OIA = 90^{0}$ នោះ $OA^2 = OI^2 + IA^2$

តាមទ្រឹស្តីបទអឺលែគេមាន $OI^2 = R(R-2r)$

តាមទ្រឹស្តីបទពីតាគ័រក្នុងត្រីកោណកែង AHI : $IA^2 = AH^2 + IH^2$

គេបាន $R^2 = R(R-2r) = r^2 + (p-a)^2$

ឬ $2rR = r^2 + (p-a)^2$

តាមរូបមន្តហេរ៉ុង $S = pr = \sqrt{p(p-a)(p-b)(p-c)} = \dfrac{abc}{4R}$

គេទាញ $2rR = \dfrac{abc}{2p}$ និង $r^2 = \dfrac{(p-a)(p-b)(p-c)}{p}$

គេបាន $\dfrac{abc}{2p} = \dfrac{(p-a)(p-b)(p-c)}{p} + (p-a)^2$

$$abc = 2(p-a)(p-b)(p-c) + 2p(p-a)^2$$

$$abc = 2(p-a)[(p-b)(p-c) + p(p-a)]$$

$$abc = (2p-2a)(p^2 - pb - pc + bc + p^2 - pa)$$

$$abc = (2p-2a)[2p^2 - p(a+b+c) + bc]$$

$$abc = (b+c-a)(2p^2 - 2p^2 + bc)$$

$$abc = bc(b+c-a)$$

$$a = b+c-a$$

គេទាញ $2a = b+c$ នោះ c, a, b ជាស្វ៊ីតនព្វន្ត ។

-សន្មតថា c, a, b ជាស្វ៊ីតនព្វន្តនោះគេបាន $2a = b+c$

តាមទ្រឹស្តីបទកូស៊ីនូសក្នុងត្រីកោណ OIA គេបាន :

$$OA^2 = OI^2 + IA^2 - 2OI.IA\cos\angle OIA$$

គេទាញ $\cos\angle OIA = \dfrac{OI^2 + IA^2 - OA^2}{2OI.IA}$

$$= \frac{R(R-2r) + r^2 + (p-a)^2 - R^2}{2OI.IA}$$

$$= \frac{r^2 - 2rR + (p-a)^2}{2OI.IA}$$

ដោយ $b + c = 2a$ នោះ $p = \dfrac{a+b+c}{2} = \dfrac{3a}{2}$

$$r^2 = \frac{(\frac{3a}{2} - a)(\frac{3a}{2} - b)(\frac{3a}{2} - c)}{\frac{3a}{2}} = \frac{a(3a-2b)(3a-2c)}{12a}$$

$$= \frac{9a^2 - 6(b+c)a + 4bc}{12} = \frac{4bc - 3a^2}{12}$$

ហើយ $R = 2rR = \dfrac{abc}{2(\frac{3a}{2})} = \dfrac{bc}{3}$

គេបាន $\cos\angle OIA = \dfrac{\frac{4bc - 3a^2}{12} - \frac{bc}{3} + (\frac{3a}{2} - a)^2}{2OI.IA} = 0$

គេបាន $\angle OIA = 90^o$ ។

ដូចនេះ $\angle OIA = 90^o$ លុះត្រាតែ AB, BC, CA ជាស្វ៊ីតនព្វន្ត ។

លំហាត់ទី៣

គេឱ្យ $\mathbf{n}$ ជាចំនួនគត់វិជ្ជមានដោយដឹងថា $\mathbf{2+2\sqrt{28n^2+1}}$ ជាចំនួនគត់។

ចូរស្រាយថា $\mathbf{2+2\sqrt{28n^2+1}}$ ជាការេប្រាកដនៃចំនួនគត់មួយ ។

ដំណោះស្រាយ

របៀបទី១

ស្រាយថា $\mathbf{2+2\sqrt{28n^2+1}}$ ជាការេប្រាកដនៃចំនួនគត់

តាមបម្រាប់ $\mathbf{2+2\sqrt{28n^2+1}}$ ជាចំនួនគត់នាំឱ្យមាន $\mathbf{m\in IN}$ ដែល

$\mathbf{28n^2+1=m^2}$ ឬ $\mathbf{m^2-28n^2=1}$ ជាសមីការ **Pell** ។

គូចម្លើយដំបូងនៃសមីការនេះគឺ $\mathbf{m=127\ ,\ n=24}$

ព្រោះ $\mathbf{127^2-28\times 24^2=1}$ ។ ចំពោះគ្រប់ $\mathbf{k\geq 1}$ គេអាចសរសេរ :

$$\mathbf{m^2-28n^2=127^2-28\times 24^2=(127-28\times 24^2)^k}$$

$$\mathbf{(m-2\sqrt{7}n)(m+2\sqrt{7}n)=(127-48\sqrt{7})^k(127+48\sqrt{7})^k}$$

គេទាញ $\begin{cases}\mathbf{m-2\sqrt{7}n=(127-48\sqrt{7})^k}\\ \mathbf{m+2\sqrt{7}n=(127+48\sqrt{7})^k}\end{cases}$

គេបានចម្លើយទូទៅនៃសមីការ :

$$\mathbf{m=\frac{(127-48\sqrt{7})^k+(127+48\sqrt{7})^k}{2}}$$

$$\mathbf{n=\frac{(127+48\sqrt{7})^k-(127-48\sqrt{7})^k}{4\sqrt{7}}}$$

ក្នុងករណីនេះគេបាន $2+2\sqrt{28n^2+1}=2+2m$

$2+2\sqrt{28n^2+1}=2+(127+48\sqrt{7})^k+(127-48\sqrt{7})^k$

ដោយ $127\pm 48\sqrt{7}=(8\pm 3\sqrt{7})^2$

និង $(8+3\sqrt{7})(8-3\sqrt{7})=1$ នោះគេបាន

$2+(127+48\sqrt{7})^k+(127-48\sqrt{7})^k=\left[(8+3\sqrt{7})^k+(8-3\sqrt{7})^k\right]^2$

គេបាន $2+2\sqrt{28n^2+1}=[(8+3\sqrt{7})^k+(8-3\sqrt{7})^k]^2$

ជាការេប្រាកដនៃចំនួនគត់ព្រោះ $(8+3\sqrt{7})^k+(8-3\sqrt{7})^k$ ជាចំនួនគត់

ដូចនេះបើ $2+2\sqrt{28n^2+1}$ ជាចំនួនគត់នោះ $2+2\sqrt{28n^2+1}$

ជាការេប្រាកដនៃចំនួនគត់ ។

របៀបទី២

ស្រាយថា $2+2\sqrt{28n^2+1}$ ជាការេប្រាកដនៃចំនួនគត់

តាមបម្រាប់ $2+2\sqrt{28n^2+1}$ ជាចំនួនគត់នាំឱ្យមាន $m\in IN$ ដែល

$28n^2+1=m^2$ ឬ $m^2-1=28n^2$

ឬ $\frac{m-1}{2}\cdot\frac{m+1}{2}=7n^2$

តាមសមីការនេះគេទាញបាន $\begin{cases}\frac{m-1}{2}=p^2\\ \frac{m+1}{2}=7q^2\end{cases}$ ឬ $\begin{cases}\frac{m-1}{2}=7p^2\\ \frac{m+1}{2}=q^2\end{cases}$

ដែល p និង q ជាចំនួនគត់វិជ្ជមាន ។

គេទាញបាន

$\mathbf{m = 2p^2 + 1 \ , \ m = 14q^2 - 1}$ ឬ $\mathbf{m = 14p^2 + 1 , m = 2q^2 - 1}$

-ករណី $\mathbf{m = 2p^2 + 1 \ , \ m = 14q^2 - 1}$

គេបាន $\mathbf{2p^2 + 1 = 14q^2 - 1}$ ឬ $\mathbf{p^2 - 7q^2 = -1}$ ជាសមីការគ្មាន

ចម្លើយក្នុង $\mathbf{IN}$ ព្រោះអង្គទីពីរសមីការចែកនឹង 7 ឱ្យសំណល់ $\mathbf{-1}$

តែអង្គទីពីរនៃសមីការចែកនឹង 7 មិនអាចឱ្យសំណល់ $\mathbf{-1}$ ទេ ព្រោះគ្រប់

ចំនួនគត់វិជ្ជមាន $\mathbf{p}$ ចំនួន $\mathbf{p^2}$ ចែកនឹង 7 ឱ្យសំណល់ $\mathbf{1 \ , \ 2 \ , \ 4}$ ។

-ករណី $\mathbf{m = 14p^2 + 1 , m = 2q^2 - 1}$

គេបាន $\mathbf{14p^2 + 1 = 2q^2 - 1}$ ឬ $\mathbf{q^2 - 7p^2 = 1}$ ជាសមីការមានចម្លើយ

ក្នុងសំណុំ $\mathbf{IN}$ ព្រោះ $\mathbf{q^2 - 7p^2}$ ចែកនឹង 7 អាចឱ្យសំណល់ $\mathbf{1}$ ។

ហេតុនេះ មានគូ $\mathbf{p , q \in IN}$ ដែល $\mathbf{m = 14p^2 + 1 , m = 2q^2 - 1}$

ក្នុងករណីនេះគេបាន $\mathbf{2 + 2\sqrt{28n^2 + 1} = 2 + 2m}$

ចំពោះ $\mathbf{m = 2q^2 - 1}$ គេបាន :

$$\mathbf{2 + 2\sqrt{28n^2 + 1} = 2 + 2(2q^2 - 1) = 4q^2}$$ ជាការេប្រាកដ ។

ឬគេអាចយក $\mathbf{m = 14p^2 + 1}$ គេបាន :

$$\mathbf{2 + 2\sqrt{28n^2 + 1} = 2 + 2(14p^2 + 1) = 28p^2 + 4}$$

$$\mathbf{= 4(7p^2 + 1) = 4q^2}$$ ជាការេប្រាកដ

ព្រោះ $\mathbf{q^2 - 7p^2 = 1}$ ឬ $\mathbf{7p^2 + 1 = q^2}$ ។

របៀបទី៣ ស្រាយថា $2+2\sqrt{28n^2+1}$ ជាការេប្រាកដនៃចំនួនគត់

តាមបម្រាប់ $2+2\sqrt{28n^2+1}$ ជាចំនួនគត់នាំឱ្យមានចំនួនគត់វិជ្ជមាន p

ដែល $28n^2+1=(2p+1)^2=4p^2+4p+1$

គេបាន $p(p+1)=7n^2$ ដោយ $GCD(p,p+1)=1$

ព្រោះ $(p+1)-p=1$ (តាមទ្រឹស្តីបទ **Bezout**)

គេទាញបាន p ចែកដាច់នឹង 7 ឬ $p+1$ ចែកដាច់នឹង 7 ។

-ករណី p ចែកដាច់នឹង 7 :

តាម $p(p+1)=7n^2$ គេទាញបាន $p=7k^2, p+1=t^2$

គ្រប់ចំនួនគត់វិជ្ជមាន k និង t ហើយ $GCD(k,t)=1$ ។

គេមាន $7k^2+1=t^2$ ឬ $t^2-7k^2=1$ ជាសមីការមានឬសក្នុង IN

ព្រោះ t^2-7k^2 ចែកនឹង 7 មានសំណល់ 1, 2 ឬ 4 ។

-ករណី $p+1$ ចែកដាច់នឹង 7 :

តាម $p(p+1)=7n^2$ គេទាញបាន $p=k^2, p+1=7t^2$

គ្រប់ចំនួនគត់វិជ្ជមាន k និង t ហើយ $GCD(k,t)=1$ ។

គេមាន $k^2+1=7t^2$ ឬ $k^2-7t^2=-1$ ជាសមីការគ្មានឬសក្នុង IN

ព្រោះ k^2-7t^2 ចែកនឹង 7 មិនអាចមានសំណល់ -1 ទេ ។

ចំពោះ $p=7k^2, p+1=t^2$ ដែល $t^2-7k^2=1$ គេមាន

$2+2\sqrt{28n^2+1}=2+2(2p+1)=4p+4=4t^2$ ជាការេ ។

លំហាត់ទី៤

គេយក $\mathbf{x}$ ជាចំនួនពិត ដោយដឹងថា $0 < x < \frac{\pi}{2}$ ។

ចូរបង្ហាញថា $\cos^2(x)\cot(x) + \sin^2(x)\tan(x) \geq 1$

(Baltic Way 2010)

ដំណោះស្រាយ

បង្ហាញថា $\cos^2(x)\cot(x) + \sin^2(x)\tan(x) \geq 1$

ដោយជំនួស $\cot x = \frac{\cos x}{\sin x}$ និង $\tan x = \frac{\sin x}{\cos x}$ វិសមភាពសមមូល

$\frac{\cos^3 x}{\sin x} + \frac{\sin^3 x}{\cos x} \geq 1$ ហើយ $\sin x > 0$, $\cos x > 0$ $\forall x \in (0, \frac{\pi}{2})$

តាមវិសមភាព $\mathbf{AM - GM}$ គេបាន :

$$\frac{\cos^3 x}{\sin x} + \frac{\cos^3 x}{\sin x} + \sin^2 x \geq 3\cos^2 x$$

ឬ $\frac{\cos^3 x}{\sin x} \geq \frac{3\cos^2 x - \sin^2 x}{2}$ **(1)**

ហើយ $\frac{\sin^3 x}{\cos x} + \frac{\sin^3 x}{\cos x} + \cos^2 x \geq 3\sin^2 x$

ឬ $\frac{\sin^3 x}{\cos x} \geq \frac{3\sin^2 x - \cos^2 x}{2}$ **(2)**

បូកវិសមភាព **(1)** និង **(2)** អង្គនិងអង្គគេបាន :

$$\frac{\cos^3 x}{\sin x}+\frac{\sin^3 x}{\cos x} \ \geq\ \cos^2 x+\sin^2 x=1$$ ពិត

ដូចនេះ $\cos^2(x)\cot(x)+\sin^2(x)\tan(x)\geq 1$ ។

លំហាត់ទី៥

គេឱ្យត្រីកោណ **ABC** មួយមានជ្រុង $\mathbf{a,b,c}$ ។ តាង $\mathbf{r}$ និង $\mathbf{R}$ រៀងគ្នាជាកាំរង្វង់ចារឹកក្នុង និង កាំរង្វង់ចារឹកក្រៅនៃ $\Delta\ \mathbf{ABC}$ ។

ក. ចូរស្រាយថា $\mathbf{a\cos A + bosB + c\cos C = \dfrac{2pr}{R}}$

$$\mathbf{\frac{\cos A}{a} + \frac{\cos B}{b} + \frac{\cos C}{c} = \frac{a^2+b^2+c^2}{2abc}}$$

$$\mathbf{\cos A + \cos B + \cos C = 1 + \frac{r}{R}}$$

ដែល $\mathbf{p = \dfrac{a+b+c}{2}}$ ជាកន្លះបរិមាត្រនៃត្រីកោណ ។

ខ. ចូរទាញបញ្ជាក់ថា $\mathbf{a^2 + b^2 + c^2 \ge 4(R+r)^2}$ ($\mathbf{A,B,C}$ ជាមុំស្រួច) ។

ដំណោះស្រាយ

ក. ស្រាយថា $\mathbf{a\cos A + bosB + c\cos C = \dfrac{2pr}{R}}$



គេមាន $\angle BAC = \frac{1}{2}\angle BOC = \angle BOK$ (មុំផ្ចិត និង មុំចារឹកក្នុងរង្វង់)

ក្នុងត្រីកោណកែង **OKB** គេមាន $\cos\angle BOK = \frac{OK}{OB} = \frac{OK}{R}$

គេទាញ $OK = R\cos\angle BOK = R\cos A$ ។

ស្រាយដូចគ្នាដែរ $OL = R\cos B$, $OM = R\cos C$

តាង **S** ជាផ្ទៃក្រឡានៃត្រីកោណ **ABC** នោះគេបាន :

$$S = S_{OBC} + S_{OCA} + S_{OAB}$$
$$pr = \frac{1}{2}BC.OK + \frac{1}{2}CA.OL + \frac{1}{2}AB.OM$$
$$pr = \frac{1}{2}aR\cos A + \frac{1}{2}bR\cos B + \frac{1}{2}cR\cos C$$
$$pr = \frac{1}{2}R(a\cos A + b\cos B + c\cos C)$$

ដូចនេះ $a\cos A + b\cos B + c\cos C = \frac{2pr}{R}$ ។

តាមទ្រឹស្តីបទកូស៊ីនូសគេមាន $a^2 = b^2 + c^2 - 2bc\cos A$

គេទាញ $\frac{\cos A}{a} = \frac{b^2 + c^2 - a^2}{2abc}$ ។

ស្រាយដូចគ្នាដែរគេបាន :

$\frac{\cos B}{b} = \frac{a^2 + c^2 - b^2}{2abc}$ និង $\frac{\cos C}{c} = \frac{a^2 + b^2 - c^2}{2abc}$

ដូចនេះ $\frac{\cos A}{a} + \frac{\cos B}{b} + \frac{\cos C}{c} = \frac{a^2 + b^2 + c^2}{2abc}$ ។

ម្យ៉ាងទៀតគេមាន :

$$\cos A+\cos B+\cos C=\frac{b^2+c^2-a^2}{2bc}+\frac{c^2+a^2-b^2}{2ac}+\frac{a^2+b^2-c^2}{2ab}$$

$$=\frac{a(b^2+c^2)+b(c^2+a^2)+c(a^2+b^2)-(a^3+b^3+c^3)}{2abc}$$

$$=\frac{(a+b+c)(a^2+b^2+c^2)-2(a^3+b^3+c^3)}{2abc}\quad (*)$$

តាមរូបមន្តហេរ៉ុងគេមាន $\sqrt{p(p-a)(p-b)(p-c)}=pr$

លើកអង្គទាំងពីរជាការេគេបាន :

$p(p-a)(p-b)(p-c)=p^2r^2$

$(p-a)(p-b)(p-c)=pr^2$

$p^3-(a+b+c)p^2+(ab+bc+ca)p-abc=pr^2$

ដោយ $a+b+c=2p$ ហើយ $S=\frac{abc}{4R}=pr$ នោះ $abc=4Rpr$

គេបាន $p^3-2p^3+(ab+bc+ca)p-4Rpr=pr^2$

គេទាញ $ab+bc+ca=p^2+r^2+4rR$

ដោយ $(a+b+c)^2=a^2+b^2+c^2+2(ab+bc+ca)$

គេបាន $a^2+b^2+c^2=4p^2-2(p^2+r^2+4rR)$

ឬ $a^2+b^2+c^2=2(p^2-r^2-4rR)$

ហើយ $a^3+b^3+c^3-3abc=(a+b+c)(a^2+b^2+c^2-ab-bc-ca)$

គេទាញបាន $a^3+b^2+c^3=2(p^3-3pr^2-6Rpr)$

ទំនាក់ទំនង **(*)** អាចសរសេរ :

$$\cos A+\cos B+\cos C=\frac{4p(p^2-r^2-4Rr)-(p^3-3pr^2-6Rpr)}{8Rpr}$$

$$=\frac{p^2-r^2-4Rr-p^2+3r^2+6Rr}{2Rr}$$

$$=\frac{2r^2+2Rr}{2Rr}=\frac{r}{R}+1$$

ដូចនេះ $\cos A+\cos B+\cos C=1+\frac{r}{R}$ ។

ខ. ទាញបញ្ជាក់ថា $a^2+b^2+c^2\geq 4(R+r)^2$

តាមវិសមភាព $\text{Cauchy}-\text{Schwarz}$ គេមាន :

$$(x_1y_1+x_2y_2+x_3y_3)^2\leq(x_1{}^2+x_2{}^2+x_3{}^2)(y_1{}^2+y_2{}^2+y_3{}^2)$$

យក $x_1=\sqrt{a\cos A}$, $x_2=\sqrt{b\cos B}$, $x_3=\sqrt{c\cos C}$

និង $y_1=\sqrt{\frac{\cos A}{a}}$, $y_2=\sqrt{\frac{\cos B}{b}}$, $z_2=\sqrt{\frac{\cos C}{c}}$ គេបាន :

$$(\cos A+\cos B+\cos C)^2\leq\frac{2pr}{R}.\frac{a^2+b^2+c^2}{2abc}$$

$$(1+\frac{r}{R})^2\leq\frac{2pr}{R}.\frac{a^2+b^2+c^2}{8Rpr}$$

$$\frac{(r+R)^2}{R^2}\leq\frac{a^2+b^2+c^2}{4R^2}$$

ដូចនេះ $a^2+b^2+c^2\geq 4(R+r)^2$ ។

លំហាត់ទី៦

គេឱ្យ $\mathbf{f}$ ជាអនុគមន៍កំណត់ពីសំណុំ $\mathbf{IR}$ ទៅសំណុំ $\mathbf{IR}_+^*$ ដែលផ្ទៀងផ្ទាត់
លក្ខខណ្ឌ $\mathbf{f(x+y)=f(x).f(y)}$ ចំពោះគ្រប់ $\mathbf{x,y\in IR}$ និង $\mathbf{f'(0)=\lambda}$
ចូរកំណត់រកអនុគមន៍ $\mathbf{y=f(x)}$ ។

ដំណោះស្រាយ

កំណត់រកអនុគមន៍ $\mathbf{y=f(x)}$

គេមាន $\mathbf{f(x+y)=f(x).f(y)}$ ចំពោះគ្រប់ $\mathbf{x,y\in IR}$

យក $\mathbf{x=y=0}$ គេបាន $\mathbf{f(0)=f^2(0)}$

នាំឱ្យ $\mathbf{f(0)[1-f(0)]=0}$ គេទាញ $\mathbf{f(0)=0}$ ឬ $\mathbf{f(0)=1}$

ដោយ $\mathbf{f}$ ជាអនុគមន៍កំណត់ពីសំណុំ $\mathbf{IR}$ ទៅសំណុំ $\mathbf{IR}_+^*$ នោះ $\mathbf{f(0)>0}$

គេបាន $\mathbf{f(0)=1}$ ។

ធ្វើដេរីវេធៀបនឹង $\mathbf{x}$ ក្នុងសមភាព $\mathbf{f(x+y)=f(x).f(y)}$ ដោយចាត់ទុក $\mathbf{y}$
ជាអថេរមិនអាស្រ័យនឹង $\mathbf{x}$ គេបាន $\mathbf{f'(x+y)=f'(x)f(y)}$

យក $\mathbf{x=0}$ គេបាន $\mathbf{f'(y)=f'(0)f(y)}$ ដោយ $\mathbf{f'(0)=\lambda}$

គេទាញបាន $\mathbf{f'(y)-\lambda f(y)=0}$ ជាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១

គេបានចម្លើយទូទៅនៃសមីការរាង $\mathbf{f(y)=k\,e^{\lambda y}}$

ចំពោះ $\mathbf{y=0}$ គេបាន $\mathbf{f(0)=k=1}$ (ព្រោះ $\mathbf{f(0)=1}$)

ដូចនេះ $\mathbf{f(x)=e^{\lambda x}}$ ជាអនុគមន៍ត្រូវរក ។

លំហាត់ទី៧

ស្វ៊ីត $\{a_n\}$ កំណត់ដោយ $a_1 = \frac{21}{16}$ និងចំពោះ $n \geq 2 : 2a_n - 3a_{n-1} = \frac{3}{2^{n+1}}$

គេយក m ជាចំនួនគត់មួយដែល $m \geq 2$ ។ ចូរបង្ហាញថាចំពោះ $n \leq m$

យើងបាន $\left(a_n + \frac{3}{2^{n+3}}\right)^{\frac{1}{m}} \left(m - \left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right) < \frac{m^2-1}{m-n+1}$?

(China National Olympiad 2005)

ដំណោះស្រាយ

បង្ហាញថា $\left(a_n + \frac{3}{2^{n+3}}\right)^{\frac{1}{m}} \left(m - \left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right) < \frac{m^2-1}{m-n+1}$

គេមាន $2a_n - 3a_{n-1} = \frac{3}{2^{n+1}}$

នាំឱ្យ $2^n a_n - 3.2^{n-1} a_{n-1} = \frac{3}{4}$

ឬ $\left(\frac{2}{3}\right)^n a_n - \left(\frac{2}{3}\right)^{n-1} a_{n-1} = \frac{3}{4} \times \frac{1}{3^n}$

គេបាន $\sum_{k=2}^{n} \left[\left(\frac{2}{3}\right)^k a_k - \left(\frac{2}{3}\right)^{k-1} a_{k-1}\right] = \frac{3}{4} \sum_{k=2}^{n} \left(\frac{1}{3^k}\right)$

$$\left(\frac{2}{3}\right)^n a_n - \frac{2}{3}a_1 = \frac{3}{4}\times\frac{1}{3^2}.\frac{1-\left(\frac{1}{3}\right)^{n-1}}{1-\frac{1}{3}}$$

$$\left(\frac{2}{3}\right)^n a_n - \frac{2}{3}.\frac{21}{16} = \frac{1}{8}\left(1-\frac{1}{3^{n-1}}\right)$$

គេទាញបាន $a_n = \left(\frac{3}{2}\right)^n - \frac{3}{2^{n+3}}$ ឬ $a_n + \frac{3}{2^{n+3}} = \left(\frac{3}{2}\right)^n$

តាង $P = \left(a_n + \frac{3}{2^{n+3}}\right)^{\frac{1}{m}}\left(m - \left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right)$

គេបាន $P = \left(\frac{3}{2}\right)^{\frac{n}{m}}\left(m - \left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right)$

គេមាន $\frac{m^2-1}{m-n+1} = \frac{(m+1)(m-1)}{(m+1)-n} = \frac{m-1}{1-\frac{n}{m+1}}$

ដើម្បីស្រាយឱ្យឃើញថា $P < \frac{m^2-1}{m-n+1}$

យើងត្រូវស្រាយឱ្យឃើញថា $(1-\frac{n}{m+1})P < m-1$

តាមវិសមភាព **Bernoully** គេមាន

$$1-\frac{n}{m+1}<(1-\frac{1}{m+1})^n=\left(\frac{m}{m+1}\right)^n=\left(\frac{1}{1+\frac{1}{m}}\right)^n$$

នាំឱ្យ $\left(1-\frac{n}{m+1}\right)^m<\left(\frac{1}{1+\frac{1}{m}}\right)^{mn}=\left[\frac{1}{(1+\frac{1}{m})^m}\right]^n$

ចំពោះគ្រប់ $m\geq 2$ តាមទ្វេធាញូតុន គេមាន :

$$\left(1+\frac{1}{m}\right)^m=1+\frac{1}{m}C_m^1+\frac{1}{m^2}C_m^2+....+\frac{1}{m^m}C_m^m$$

នោះ $\left(1+\frac{1}{m}\right)^m\geq 1+\frac{1}{m}C_m^1+\frac{1}{m^2}C_m^2=\frac{5}{2}-\frac{1}{2m}\geq\frac{9}{4}=\left(\frac{3}{2}\right)^2$

គេទាញបាន $\left(1-\frac{n}{m+1}\right)^m<\left(\frac{2}{3}\right)^{2n}$ ឬ $1-\frac{n}{m+1}<\left(\frac{2}{3}\right)^{\frac{2n}{m}}$

គេទាញ $\left(1-\frac{n}{m+1}\right)P<\left(\frac{2}{3}\right)^{\frac{2n}{m}}P$

តែ $P=\left(\frac{3}{2}\right)^{\frac{n}{m}}\left(m-\left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right)$

គេបាន $(1-\frac{n}{m+1})P<\left(\frac{2}{3}\right)^{\frac{n}{m}}\left(m-\left(\frac{2}{3}\right)^{\frac{n}{m}(m-1)}\right)$

ឧបមាថា $\left(\frac{2}{3}\right)^{\frac{n}{m}}\left(m-\left(\frac{2}{3}\right)^{\frac{n}{m}(m-1)}\right) < m-1$ ពិត

ដោយតាង $u=\left(\frac{2}{3}\right)^{\frac{n}{m}}$ នោះ $u(m-u^{m-1}) < m-1$

សមមូល $mu-u^{m}-m+1<0$

$$m(u-1)-(u^{m}-1)<0$$

$$(u-1)[m-(u^{m-1}+....+u+1)]<0$$

ដោយ $m\geq n$ & $m\geq 2$ នោះ $0<u=\left(\frac{2}{3}\right)^{\frac{n}{m}}<1$

នាំឱ្យ $(u-1)[m-(u^{m-1}+....+u+1)]<0$ ពិត

ដូចនេះ $\left(a_n+\frac{3}{2^{n+3}}\right)^{\frac{1}{m}}\left(m-\left(\frac{2}{3}\right)^{\frac{n(m-1)}{m}}\right)<\frac{m^2-1}{m-n+1}$

លំហាត់ទី៨

គេឱ្យ a, b, c ជាចំនួនពិតវិជ្ជមានដែល $a+b+c=3$ ។

ចូរស្រាយបញ្ជាក់វិសមភាព $\frac{a^2}{a+b^2}+\frac{b^2}{b+c^2}+\frac{c^2}{c+a^2}\geq\frac{3}{2}$

(Croatia Team Selection Tests 2011)

ដំណោះស្រាយ

ស្រាយបញ្ជាក់វិសមភាព $\frac{a^2}{a+b^2}+\frac{b^2}{b+c^2}+\frac{c^2}{c+a^2}\geq\frac{3}{2}$

គេមាន $\frac{a^2}{a+b^2}=\frac{a(a+b^2)-ab^2}{a+b^2}=a-\frac{ab^2}{a+b^2}\quad(1)$

ដូចគ្នាដែរ $\frac{b^2}{b+c^2}=b-\frac{bc^2}{b+c^2}(2)\ ;\ \frac{c^2}{c+a^2}=c-\frac{ca^2}{c+a^2}\ (3)$

តាង $S=\frac{a^2}{a+b^2}+\frac{b^2}{b+c^2}+\frac{c^2}{c+a^2}$ ។ បូកវិសមភាព $(1),(2)\,\&\,(3)$

គេបាន $S=3-(\frac{ab^2}{a+b^2}+\frac{bc^2}{b+c^2}+\frac{ca^2}{c+a^2})$

ដើម្បីស្រាយថា $S\geq\frac{3}{2}$ នោះយើងនឹងស្រាយថា :

$$\frac{ab^2}{a+b^2}+\frac{bc^2}{b+c^2}+\frac{ca^2}{c+a^2}=3-S\leq 3-\frac{3}{2}=\frac{3}{2}$$ ។

តាមវិសមភាព $AM-GM$ គេមាន $a+b^2\geq 2b\sqrt{a}=\frac{2ab^2}{b\sqrt{a}}$

គេទាញ $\frac{ab^2}{a+b^2} \le \frac{b\sqrt{a}}{2}$ ហើយ $\frac{bc^2}{b+c^2} \le \frac{c\sqrt{b}}{2}$, $\frac{ca^2}{c+a^2} \le \frac{a\sqrt{c}}{2}$

ហេតុនេះ $\frac{ab^2}{a+b^2} + \frac{bc^2}{b+c^2} + \frac{ca^2}{c+a^2} \le \frac{1}{2}(a\sqrt{c} + b\sqrt{a} + c\sqrt{b})$ (*)

តាមវិសមភាព **Cauchy – Schwarz** គេមាន :

$$(a\sqrt{c} + b\sqrt{a} + c\sqrt{b})^2 \le (a+b+c)(ab+bc+ca)$$

$$(a\sqrt{c} + b\sqrt{a} + c\sqrt{b})^2 \le 3(ab+bc+ca)$$

ហើយ $(ab+bc+ca)^2 \le (a^2+b^2+c^2)(b^2+c^2+a^2)$

$$(ab+bc+ca)^2 \le (a^2+b^2+c^2)^2$$

$$ab+bc+ca \le a^2+b^2+c^2$$

$$ab+bc+ca \le (a+b+c)^2 - 2(ab+bc+ca)$$

$$3(ab+bc+ca) \le (a+b+c)^2 = 9$$

គេទាញ $(a\sqrt{c} + b\sqrt{a} + c\sqrt{b})^2 \le 3(ab+bc+ca) \le 9$

នាំឱ្យ $a\sqrt{c} + b\sqrt{a} + c\sqrt{b} \le 3$ (**)

តាមវិសមភាព (*) & (**) គេទាញបាន :

$\frac{ab^2}{a+b^2} + \frac{bc^2}{b+c^2} + \frac{ca^2}{c+a^2} \le \frac{3}{2}$ ពិត

ដូចនេះ $\frac{a^2}{a+b^2} + \frac{b^2}{b+c^2} + \frac{c^2}{c+a^2} \ge \frac{3}{2}$ ។

លំហាត់ទី៩

គេឱ្យ a,b,c ជាជ្រុងរបស់ត្រីកោណមួយ ។ ចូរស្រាយថា :

$$\frac{(c+a-b)^4}{a(a+b-c)}+\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)}\geq ab+bc+ca$$

(Greece National Olympiad 2007)

ដំណោះស្រាយ

ស្រាយថា :

$$\frac{(c+a-b)^4}{a(a+b-c)}+\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)}\geq ab+bc+ca$$

តាមវិសមភាព $\mathbf{AM-GM}$ គេមាន :

$$\frac{(c+a-b)^4}{a(a+b-c)}+a(a+b-c)\geq 2(c+a-b)^2$$

គេទាញ $\frac{(c+a-b)^4}{a(a+b-c)}\geq 2(c+a-b)^2-a(a+b-c)$

ឬ $\frac{(c+a-b)^4}{a(a+b-c)}\geq a^2+2b^2+2c^2+5ac-5ab-4bc \quad (1)$

ស្រាយដូចគ្នាដែរគេបាន :

$$\frac{(a+b-c)^4}{b(b+c-a)}\geq 2a^2+b^2+2c^2+5ab-5bc-4ac \quad (2)$$

$$\frac{(b+c-a)^4}{c(c+a-b)}\geq 2a^2+2b^2+c^2+5bc-5ac-4ab \quad (3)$$

បូកវិសមភាព **(1) , (2) & (3)** គេបាន :

$$\mathbf{S \ge 5(a^2+b^2+c^2)-4(ab+bc+ca) \ge ab+bc+ac}$$ ពិត

ដូចនេះ $\mathbf{S=\frac{(c+a-b)^4}{a(a+b-c)}+\frac{(a+b-c)^4}{b(b+c-a)}+\frac{(b+c-a)^4}{c(c+a-b)} \ge ab+bc+ca}$ ។

លំហាត់ទី១០

គេឱ្យ f ជាអនុគមន៍កំណត់ពី $(0,+\infty)$ ទៅ IR ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ

$f(x)+f(y)=f(xy)$ គ្រប់ $x>0, y>0$ និង $f'(1)=\lambda$ ។

ចូរកំណត់រកអនុគមន៍ $y=f(x)$ ។

ដំណោះស្រាយ

កំណត់រកអនុគមន៍ $y=f(x)$

គេមាន $f(x)+f(y)=f(xy)$ គ្រប់ $x>0, y>0$

យក $y=0$ គេបាន $f(x)+f(1)=f(x)$ នាំឱ្យ $f(1)=0$

ធ្វើដេរីវេធៀបនឹង x ក្នុងសមភាព $f(x)+f(y)=f(xy)$ ដោយចាត់ទុក y

ជាអថេរមិនអាស្រ័យនឹង x គេបាន $f'(x)=yf'(xy)$

យក $x=1$ គេបាន $f'(1)=yf'(y)$ ដោយ $f'(1)=\lambda$ នោះ $f'(y)=\dfrac{\lambda}{y}$

គេទាញបាន $f(y)=\int \dfrac{\lambda}{y}dy=\lambda\ln|y|+k$

យក $y=1$ នោះ $f(1)=k=0$ ព្រោះ $f(1)=0$ ។

ហេតុនេះ $f(y)=\lambda\ln|y|=\lambda\ln y$ គ្រប់ $y>0$

ដូចនេះ $f(x)=\lambda.\ln x$ ជាអនុគមន៍ត្រូវរក ។

លំហាត់ទី១១

គេកំណត់ចំនួន $a_0, a_1, a_2, ..., a_n$ ដូចខាងក្រោម :

$$a_0 = \frac{1}{2}; a_{k+1} = a_k + \frac{a_k^2}{n} \quad (n > 1, k = 0, 1, 2, ..., n-1)$$

ចូរបង្ហាញថា $1 - \frac{1}{n} < a_n < 1$ ។

(IMO Longlists 1980)

ដំណោះស្រាយ

បង្ហាញថា $1 - \frac{1}{n} < a_n < 1$

គេមាន $a_{k+1} = a_k + \frac{a_k^2}{n} = \frac{a_k(n + a_k)}{n}$

គេបាន $\frac{1}{a_{k+1}} = \frac{n}{a_k(a_k + n)} = \frac{1}{a_k} - \frac{1}{a_k + n}$

ឬ $\frac{1}{a_k + n} = \frac{1}{a_k} - \frac{1}{a_{k+1}}$

ហេតុនេះ $\sum_{k=0}^{n-1} \frac{1}{a_k + n} = \sum_{k=0}^{n-1} (\frac{1}{a_k} - \frac{1}{a_{k+1}}) = \frac{1}{a_0} - \frac{1}{a_n} = 2 - \frac{1}{a_n}$ (*)

គេមាន $a_0 = \frac{1}{2} > 0$ ពិត ។ ឧបមាថា $a_k > 0$ ពិត

តាម $a_{k+1} = a_k + \frac{a_k^2}{n}$ គេទាញបាន $a_{k+1} > 0$ ពិត

ដូចនេះ $a_k > 0$ នោះ $a_k + n > n$ ឬ $\frac{1}{a_k + n} < \frac{1}{n}$,$\forall n > 1$

គេបាន $\sum_{k=0}^{n-1} \frac{1}{a_k + n} < \sum_{k=0}^{n-1} \frac{1}{n} = \underbrace{\frac{1}{n} + \frac{1}{n} + ... + \frac{1}{n}}_{(n)} = \frac{n}{n} = 1$

តាម (*) គេទាញបាន $2 - \frac{1}{a_n} < 1$ នាំឱ្យ $a_n < 1$ (i)

ម្យ៉ាងទៀតដោយ $a_n < 1$ នោះ $a_k < 1$ ឬ $a_k + n < n + 1$

ឬ $\frac{1}{a_k + n} > \frac{1}{n+1}$ គ្រប់ $k = 0, 1, 2, ..., n-1$ ។

គេបាន $\sum_{k=0}^{n-1} \frac{1}{a_k + n} > \sum_{k=0}^{n-1} \frac{1}{n+1} = \frac{n}{n+1}$

ដោយពិនិត្យឃើញថាគ្រប់ $n > 1$ គេមាន $\frac{n}{n+1} - \frac{n-2}{n-1} = \frac{2}{n^2 - 1} > 0$

នោះគេទាញបាន $\sum_{k=0}^{n-1} \frac{1}{a_k + n} > \frac{n}{n+1} > \frac{n-2}{n-1}$

តាម (*) គេទាញបាន $2 - \frac{1}{a_n} > \frac{n-2}{n-1}$

ឬ $\frac{1}{a_n} < 2 - \frac{n-2}{n-1} = \frac{n}{n-1}$ នោះ $a_n > \frac{n-1}{n} = 1 - \frac{1}{n}$ (ii)

តាម (i) & (ii) គេទាញបាន $1 - \frac{1}{n} < a_n < 1$ ។

ដូចនេះ $1 - \frac{1}{n} < a_n < 1$ ។

លំហាត់ទី១២

គេឱ្យ f ជាអនុគមន៍ជាប់ និង មានដេរីវេលើ IR ដែលចំពោះគ្រប់ $x,y \in IR$ គេមានទំនាក់ទំនង $f(x+y)=\frac{f(x)+f(y)}{1+f(x)f(y)}$ និង $f(x)\neq \pm 1$ គ្រប់ x ។

ចូរកំណត់អនុគមន៍ $y=f(x)$ ។

ដំណោះស្រាយ

កំណត់អនុគមន៍ $y=f(x)$

គេមាន $f(x+y)=\frac{f(x)+f(y)}{1+f(x)f(y)}$

យក $y=0$ គេបាន $f(x)=\frac{f(x)+f(0)}{1+f(x)f(0)}$

ឬ $f(x)+f^2(x)f(0)=f(x)+f(0)$

ឬ $f(0)[f^2(x)-1]=0$ គេទាញបាន $f(0)=0$ ឬ $f(x)=\pm 1$

ដោយតាមសម្មតិកម្ម $f(x)\neq \pm 1$ នោះ $f(0)=0$ ។

ធ្វើដេរីវេធៀបនឹង x ក្នុងសមភាព $f(x+y)=\frac{f(x)+f(y)}{1+f(x)f(y)}$

ដោយចាត់ទុក y ជាអថេរមិនអាស្រ័យនឹង x គេបាន :

$$f'(x+y)=\frac{f'(x)[1+f(x)f(y)]-f'(x)f(y)[f(x)+f(y)]}{[1+f(x)f(y)]^2}$$

$$f'(x+y)=\frac{f'(x)[1-f^2(y)]}{[1+f(x)f(y)]^2}$$

យក $x=0$ គេបាន $f'(y)=\dfrac{f'(0)[1-f^2(y)]}{[1+f(0)f(y)]^2}$ ដោយ $f(0)=0$

គេបាន $f'(y)=f'(0)[1-f^2(y)]$ តាង $f'(0)=\lambda$

គេបាន $\dfrac{f'(y)}{1-f^2(y)}=\lambda$ (ព្រោះ $f(y)\neq\pm1$)

ធ្វើអាំងតេក្រាលធៀបនឹង y លើអង្គទាំងពីរនៃសមីការខាងលើគេបាន :

$$\int\frac{f'(y)dy}{1-f^2(y)}=\int\lambda dy=\lambda y+k$$

តាង $z=f(y)$ នោះ $dz=f'(y)dy$

គេបាន $\displaystyle\int\frac{f'(y)dy}{1-f^2(y)}=\int\frac{dz}{1-z^2}=\frac{1}{2}\int\left(\frac{1}{1-z}+\frac{1}{1+z}\right)dz$

$$=\frac{1}{2}\int\frac{dz}{1-z}+\frac{1}{2}\int\frac{dz}{1+z}$$

$$=\frac{1}{2}\ln|1-z|+\frac{1}{2}\ln|1+z|$$

$$=\frac{1}{2}\ln\left|\frac{1-z}{1+z}\right|=\frac{1}{2}\ln\left|\frac{1-f(y)}{1+f(y)}\right|$$

គេទាញ $\dfrac{1}{2}\ln\left|\dfrac{1-f(y)}{1+f(y)}\right|=\lambda y+k$

ចំពោះ $y=0$ គេបាន $\dfrac{1}{2}\ln\left|\dfrac{1-f(0)}{1+f(0)}\right|=k$ នាំឱ្យ $k=0$ ព្រោះ $f(0)=0$

ហេតុនេះ $\dfrac{1}{2}\ln\left|\dfrac{1-f(y)}{1+f(y)}\right|=\lambda y$

គេទាញបាន $\dfrac{1-f(y)}{1+f(y)}=e^{2\lambda y}$ **(1)** ឬ $\dfrac{1-f(y)}{1+f(y)}=e^{-2\lambda y}$ **(2)**

តាម **(1)** គេបាន $1-f(y)=e^{2\lambda y}+f(y)e^{2\lambda y}$

នាំឱ្យ $f(y)=\dfrac{1-e^{2\lambda y}}{1+e^{2\lambda y}}$ ។

តាម **(2)** គេបាន $1-f(y)=e^{-2\lambda y}+f(y)e^{-2\lambda y}$

នាំឱ្យ $f(y)=\dfrac{1-e^{-2\lambda y}}{1+e^{-2\lambda y}}$ ។

ដូចនេះ $f(x)=\dfrac{1-e^{2\lambda x}}{1+e^{2\lambda x}}$ ឬ $f(x)=\dfrac{1-e^{-2\lambda x}}{1+e^{-2\lambda x}}$ ដែល $\lambda=f'(0)$ ។

លំហាត់ទី១៣

ចូរបង្ហាញថា :

$$\log_a bc + \log_b ca + \log_c ab \ge 4(\log_{ab} c + \log_{bc} a + \log_{ca} b)$$

ចំពោះគ្រប់ a, b, c ធំជាងមួយ ។

(Malaysia National Olympiad 2010)

ដំណោះស្រាយ

ការបង្ហាញ :

តាង $A = \log_a bc + \log_b ca + \log_c ab$

និង $B = 4(\log_{ab} c + \log_{bc} a + \log_{ca} b)$

ហើយយក $x = \ln a$, $y = \ln b$, $z = \ln c$

ចំពោះ $a, b, c > 1$ នោះ $x, y, z > 0$

តាមរូបមន្តប្តូរគោល $\log_q p = \dfrac{\ln p}{\ln q}$ គេបាន :

$$A = \frac{y+z}{x} + \frac{z+x}{y} + \frac{x+y}{z} = x\left(\frac{1}{y} + \frac{1}{z}\right) + y\left(\frac{1}{z} + \frac{1}{x}\right) + z\left(\frac{1}{x} + \frac{1}{y}\right)$$

$$B = 4\left(\frac{z}{x+y} + \frac{x}{y+z} + \frac{y}{z+x}\right) = \frac{4x}{y+z} + \frac{4y}{z+x} + \frac{4z}{x+y}$$

តាមវិសមភាព $\mathbf{AB-GM}$ គ្រប់ $\mathbf{u\,,v>0 : u+v\geq 2\sqrt{uv}}$

ឬ $\mathbf{(u+v)^2\geq 4uv}$ ឬ $\mathbf{\frac{u+v}{uv}\geq\frac{4}{u+v}}$ ឬ $\mathbf{\frac{1}{u}+\frac{1}{v}\geq\frac{4}{u+v}}$

គេទាញ $\mathbf{x(\frac{1}{y}+\frac{1}{z})\geq\frac{4x}{y+z};y(\frac{1}{z}+\frac{1}{x})\geq\frac{4y}{z+x};z(\frac{1}{x}+\frac{1}{y})\geq\frac{4z}{x+y}}$

បូកវិសមភាពនេះគេបាន $\mathbf{A\geq B}$ ពិត ។

ដូចនេះ

$$\mathbf{\log_a bc+\log_b ca+\log_c ab\geq 4(\log_{ab} c+\log_{bc} a+\log_{ca} b)}$$

លំហាត់ទី១៤

គេឱ្យរង្វង់ផ្ចិត **O** កាំ **r** និងត្រីកោណ **ABC** ប្រែប្រួលចារឹកក្រៅរង្វង់ ។ បន្ទាត់កាត់តាម **O** កាត់ជ្រុង **AB** និង **AC** រៀងគ្នាត្រង់ **M** និង **N** ។ កំណត់ទីតាំងចំណុច **A** និងអង្កត់ **[MN]** ដើម្បីឱ្យផ្ទៃក្រឡាត្រីកោណ **AMN** មានតម្លៃតូចបំផុត ?

(ប្រឡងសិស្សពូកែប្រចាំរាជធានីភ្នំពេញ ២០០៩)

ដំណោះស្រាយ

កំណត់ទីតាំងចំណុច **A** និងអង្កត់ **[MN]**

តាង S_{AMN} ជាក្រឡាផ្ទៃនៃត្រីកោណ **AMN** ហើយ **A', B' , C'** ជាចំណោលកែងនៃ **O** លើជ្រុង BC, CA, AB រៀងគ្នា ។

យើងបាន :

$$S_{AMN} = \frac{1}{2}AM.AN.\sin A = \frac{1}{2}r(AM + AN)$$

គេទាញបាន $AM.AN.\sin A = r(AM + AN)$

តាមវិសមភាព $AM - GM$ គេមាន $AM + AN \geq 2\sqrt{AM.AN}$

គេបាន $\mathbf{AM.AN.\sin A \geq 2r\sqrt{AM.AN}}$

ឬ $\mathbf{AM^2.AN^2.\sin^2 A \geq 4r^2.AM.AN}$

គេទាញបាន $\mathbf{AM.AN.\sin A \geq \dfrac{4r^2}{\sin A}}$

ហេតុនេះ $\mathbf{S_{AMN} \geq \dfrac{4r^2}{\sin A}}$

ដើម្បីឱ្យផ្ទៃក្រឡាត្រីកោណ $\mathbf{AMN}$ មានតម្លៃតូចបំផុតលុះត្រាតែ $\mathbf{\sin A = 1}$

គេទាញបាន $\mathbf{A = 90^o}$ ។

ក្នុងករណីនេះធ្វើឱ្យវិសមភាព $\mathbf{AM + AN \geq 2\sqrt{AM.AN}}$ ក្លាយជាសមភាព

គឺ $\mathbf{AM = AN}$ ហេតុនេះ $\mathbf{AMN}$ គឺជាត្រីកោណសមបាតកំពូល ។

ដោយ $\mathbf{OA}$ ជាកន្លះបន្ទាត់ពុះក្នុងនៃមុំ $\mathbf{\angle BAC}$ នោះ $\mathbf{OA \perp MN}$

ហេតុនេះ $\mathbf{OM = ON}$ នាំឱ្យ $\mathbf{MN = 2.OM}$

ក្នុងត្រីកោណកែង $\mathbf{OMC'}$ គេមាន $\mathbf{\sin\angle OMC' = \dfrac{OC'}{OM} = \dfrac{r}{OM}}$

ដោយ $\mathbf{\angle OMC' = 45^o}$ នោះ $\mathbf{OM = \sqrt{2}\ r}$

គេទាញបាន $\mathbf{MN = 2\sqrt{2}\,r}$ ។

សន្និដ្ឋាន :

ដោយមុំ $\mathbf{\angle MAN = 90^o}$ នោះចំនុច $\mathbf{M}$ គឺជាកន្លះរង្វង់មានផ្ចិត $\mathbf{O}$ និងមាន

វិជ្ឈមាត្រ $\mathbf{MN = 2\sqrt{2}\,r}$ ។

លំហាត់ទី១៥

គេតាង α,β,γ ជារង្វាស់មុំក្នុងត្រីកោណ **ABC** មួយដែលមានបរិមាត្រ **2p** និងកាំរង្វង់ចារឹកក្រៅ **R** ។

a/ ចូរស្រាយបញ្ជាក់ថា $\cot^2\alpha+\cot^2\beta+\cot^2\gamma\geq 3\left(9.\frac{R^2}{p^2}-1\right)$

b/ តើពេលណាទើបគេបានសមភាព ?

(Morocco National Olympiad 2011)

ដំណោះស្រាយ

a/ ស្រាយបញ្ជាក់ថា $\cot^2\alpha+\cot^2\beta+\cot^2\gamma\geq 3\left(9.\frac{R^2}{p^2}-1\right)$

គេមាន $\frac{1}{\sin^2\alpha}+\frac{1}{\sin^2\beta}+\frac{1}{\sin^2\gamma}=3+\cot^2\alpha+\cot^2\beta+\cot^2\gamma$

យើងនឹងស្រាយថា $\frac{1}{\sin^2\alpha}+\frac{1}{\sin^2\beta}+\frac{1}{\sin^2\gamma}\geq\frac{27R^2}{p^2}$

តាមវិសមភាព **Cauchy – Schwarz** គេមាន :

$$\frac{1}{\sin^2\alpha}+\frac{1}{\sin^2\beta}+\frac{1}{\sin^2\gamma}\geq\frac{1}{3}\left(\frac{1}{\sin\alpha}+\frac{1}{\sin\beta}+\frac{1}{\sin\gamma}\right)^2\quad(1)$$

ដោយប្រើ $\frac{a_1^2}{b_1}+\frac{a_2^2}{b_2}+\frac{a_3^2}{b_3}\geq\frac{(a_1+a_2+a_3)^2}{b_1+b_2+b_3}$

គេបាន $\dfrac{1}{\sin\alpha}+\dfrac{1}{\sin\beta}+\dfrac{1}{\sin\gamma}\ge\dfrac{9}{\sin\alpha+\sin\beta+\sin\gamma}$

តាមទ្រឹស្ដីបទស៊ីនុសអនុវត្តន៍ក្នុង $\Delta\,ABC$ គេបាន :

$$\frac{a}{\sin\alpha}=\frac{b}{\sin\beta}=\frac{c}{\sin\gamma}=\frac{a+b+c}{\sin\alpha+\sin\beta+\sin\gamma}=2R$$

គេទាញ $\sin\alpha+\sin\beta+\sin\gamma=\dfrac{a+b+c}{2R}=\dfrac{p}{R}$

ហេតុនេះ $\dfrac{1}{\sin\alpha}+\dfrac{1}{\sin\beta}+\dfrac{1}{\sin\gamma}\ge\dfrac{9}{\sin\alpha+\sin\beta+\sin\gamma}=\dfrac{9R}{p}$ (2)

តាម (1) & (2) គេទាញបាន :

$$\frac{1}{\sin^2\alpha}+\frac{1}{\sin^2\beta}+\frac{1}{\sin^2\gamma}\ge\frac{1}{3}\times\frac{81R^2}{p^2}=\frac{27R^2}{p^2}$$ ពិត

ដូចនេះ $\cot^2\alpha+\cot^2\beta+\cot^2\gamma\ge 3\left(9.\dfrac{R^2}{p^2}-1\right)$ ។

b / វិសមភាពនេះក្លាយជាសមភាពលុះត្រាតែ $\dfrac{1}{\sin\alpha}=\dfrac{1}{\sin\beta}=\dfrac{1}{\sin\gamma}$

គេទាញបាន $\alpha=\beta=\gamma$ នាំឱ្យ ΔABC ជាត្រីកោណសមង្ស័ ។

លំហាត់ទី១៦

គេឱ្យម៉ាទ្រីស $\mathbf{A}=\begin{bmatrix}3&1&1\\1&3&1\\1&1&3\end{bmatrix}$ និង $\mathbf{I}=\begin{bmatrix}1&0&0\\0&1&0\\0&0&1\end{bmatrix}$

បង្ហាញថាមានស្វ៊ីតចំនួនពិតពីរ $(\mathbf{u_n})$ និង $(\mathbf{v_n})$ ដែលផ្ទៀងផ្ទាត់ :

$\forall \mathbf{n}\in \mathbf{IN}:\ \mathbf{A^n}=\mathbf{u_n.I}+\mathbf{v_n.A}$ ដែលគេនឹងបញ្ជាក់តួទូទៅ $\mathbf{u_n}$ និង $\mathbf{v_n}$ ជាអនុគមន៍នៃ $\mathbf{n}$ ។

ដំណោះស្រាយ

បង្ហាញថា $\forall \mathbf{n}\in \mathbf{IN}:\ \mathbf{A^n}=\mathbf{u_n.I}+\mathbf{v_n.A}$

គេមាន $\mathbf{A}=\begin{bmatrix}3&1&1\\1&3&1\\1&1&3\end{bmatrix}=0.\begin{bmatrix}1&0&0\\0&1&0\\0&0&1\end{bmatrix}+1.\begin{bmatrix}3&1&1\\1&3&1\\1&1&3\end{bmatrix}$

គេបាន $\mathbf{A^1}=\mathbf{u_1.I}+\mathbf{v_1.A}$ ពិតចំពោះ $\mathbf{n}=1$ ដែល $\mathbf{u_1}=0$, $\mathbf{v_1}=1$ ។

$$\mathbf{A^2}=\mathbf{A.A}=\begin{bmatrix}3&1&1\\1&3&1\\1&1&3\end{bmatrix}.\begin{bmatrix}3&1&1\\1&3&1\\1&1&3\end{bmatrix}=\begin{bmatrix}11&7&7\\7&11&7\\7&7&11\end{bmatrix}$$

$$\mathbf{A^2}=\begin{bmatrix}-10&0&0\\0&-10&0\\0&0&-10\end{bmatrix}+\begin{bmatrix}21&7&7\\7&21&7\\7&7&21\end{bmatrix}=-10.\mathbf{I}+7.\mathbf{A}$$

គេបាន $\mathbf{A^2}=\mathbf{u_2.I}+\mathbf{v_2.A}$ ពិតចំពោះ $\mathbf{n}=2$ ។

ឧបមាថាវាពិតចំពោះគ្រប់ $\mathbf{n \in IN}$ គឺ $\mathbf{A^n = u_n.I + v_n.A}$

យើងនឹងស្រាយថា $\mathbf{A^{n+1} = u_{n+1}.I + v_{n+1}.A}$ ពិត ។

គេមាន $\mathbf{A^{n+1} = A.A^n = A.(u_n.I + v_n.A) = u_n.A.I + v_n.A^2}$

ដោយ $\mathbf{A.I = A}$ និង $\mathbf{A^2 = u_2.I + v_2.A}$

គេបាន $\mathbf{A^{n+1} = u_n.A + v_n(u_2.I + v_2.A)}$

$$\mathbf{A^{n+1} = u_2 v_n.I + (u_n + v_2 v_n).A}$$

$$\mathbf{A^{n+1} = u_{n+1}.I + v_{n+1}.A} \text{ ពិត}$$

ដែល $\mathbf{u_{n+1} = u_2 v_n = -10.v_n}$ និង $\mathbf{v_{n+1} = u_n + v_2 v_n = u_n + 7v_n}$

ដូចនេះ $\mathbf{\forall n \in IN :\ A^n = u_n.I + v_n.A}$

ដែល (u_n) និង (v_n) ជាស្វ៊ីតចំនួនពិតពីរកំណត់ដោយ $u_1 = 0$, $v_1 = 1$

និង $u_{n+1} = -10.v_n$, $v_{n+1} = u_n + 7v_n$ គ្រប់ $n \in IN$ ។

បញ្ជាក់តួទូទៅ $\mathbf{u_n}$ *និង* $\mathbf{v_n}$ *ជាអនុគមន៍នៃ* $\mathbf{n}$ *:*

គេមាន $\mathbf{u_{n+1} = -10.v_n}$, $\mathbf{v_{n+1} = u_n + 7v_n}$ គ្រប់ $\mathbf{n \in IN}$

តាម $\mathbf{v_{n+1} = u_n + 7v_n}$ គេបាន $\mathbf{v_{n+2} = u_{n+1} + 7v_{n+1}}$

តែ $\mathbf{u_{n+1} = -10v_n}$ នោះ $\mathbf{v_{n+2} = 7v_{n+1} - 10v_n}$

សមីការសម្គាល់នៃ $\mathbf{v_{n+2} = 7v_{n+1} - 10v_n}$ គឺ $\mathbf{r^2 = 7r - 10}$

ឬ $\mathbf{r^2 - 7r + 10 = 0}$ មានឫស $\mathbf{r_1 = 2}$, $\mathbf{r_2 = 5}$ ។

តាងស្វ៊ីតជំនួយ $\begin{cases} a_n = v_{n+1} - 2v_n \\ b_n = v_{n+1} - 5v_n \end{cases}$

គេបាន $\begin{cases} a_{n+1} = v_{n+2} - 2v_{n+1} = 7v_{n+1} - 10v_n - 2v_{n+1} = 5a_n \\ b_{n+1} = v_{n+2} - 5v_{n+1} = 7v_{n+1} - 10v_n - 5v_{n+1} = 2b_n \end{cases}$

នាំឱ្យ (a_n) និង (b_n) ជាស្វ៊ីតធរណីមាត្រមានរេសុង 5 និង 2 រៀងគ្នា ។

គេបាន $a_n = a_1.5^{n-1}$ និង $b_n = b_1.2^{n-1}$ ។

ដោយ $a_1 = v_2 - 2v_1 = 7 - 2 = 5$ និង $b_1 = v_2 - 5v_1 = 7 - 2 = 2$

គេទាញ $a_n = 5.5^{n-1} = 5^n$ និង $b_n = 2.2^{n-1} = 2^n$ ។

គេបានប្រព័ន្ធ $\begin{cases} v_{n+1} - 2v_n = 5^n \\ v_{n+1} - 5v_n = 2^n \end{cases}$

ដកសមីការពីរនេះគេបាន $3v_n = 5^n - 2^n$ នាំឱ្យ $v_n = \dfrac{5^n - 2^n}{3}$

ហើយ $u_{n+1} = -10v_n = -\dfrac{10}{3}(5^n - 2^n)$

នាំឱ្យ $u_n = -\dfrac{10}{3}(5^{n-1} - 2^{n-1})$ ។

ដូចនេះ $u_n = -\dfrac{10}{3}(5^{n-1} - 2^{n-1})$ និង $v_n = \dfrac{5^n - 2^n}{3}$ ។

លំហាត់ទី១៧

គេឱ្យ f ជាអនុគមន៍ជាប់ និង មានដេរីវេលើ IR ដែលចំពោះគ្រប់ $x,y\in IR$

គេមានទំនាក់ទំនង $f(\frac{x+y}{2})=\sqrt{f(x)f(y)}$ និង $f(x)>0$ ។

ចូរកំណត់អនុគមន៍ $y=f(x)$ ។

ដំណោះស្រាយ

កំណត់អនុគមន៍ $y=f(x)$

គេមានទំនាក់ទំនង $f(\frac{x+y}{2})=\sqrt{f(x)f(y)}$

ដោយ $f(x)>0$ នោះ $f(y)>0$ និង $f(\frac{x+y}{2})>0$

តាងអនុគមន៍ $g(x)=\ln f(x)$ ចំពោះគ្រប់ $x\in IR$

គេបាន $g(\frac{x+y}{2})=\ln\left[f(\frac{x+y}{2})\right]$ ដោយ $f(\frac{x+y}{2})=\sqrt{f(x)f(y)}$

ហេតុនេះ $g(\frac{x+y}{2})=\ln\left[\sqrt{f(x)f(y)}\right]=\frac{1}{2}\left[\ln f(x)+\ln f(y)\right]$

ឬ $g(\frac{x+y}{2})=\frac{1}{2}\left[g(x)+g(y)\right]$

ធ្វើដេរីវេធៀបនឹង x ក្នុងសមភាព $g(\frac{x+y}{2})=\frac{1}{2}\left[g(x)+g(y)\right]$

ដោយចាត់ទុក y ជាអថេរមិនអាស្រ័យនឹង x គេបាន :

$$\frac{1}{2}g'(\frac{x+y}{2})=\frac{1}{2}g'(x) \text{ ឬ } g'(\frac{x+y}{2})=g'(x)$$

យក $x=0$ គេបាន $g'(\frac{y}{2})=g'(0)$

ធ្វើអាំងតេក្រាល $\int g'(\frac{y}{2})dy=\int g'(o)dy=g'(0)y+k$

តាង $z=\frac{y}{2}$ នោះ $dy=2dz$

គេបាន $2\int g'(z)dz=g'(0)y+k$

$$2g(z)=g'(0)y+k \text{ ឬ } g(z)=\frac{1}{2}g'(0)y+\frac{k}{2}=g'(0)z+\frac{k}{2}$$

យក $a=g'(0)$ និង $b=\frac{k}{2}$ គេបាន $g(z)=az+b$

ឬ $g(x)=ax+b$ ដោយ $g(x)=\ln f(x)$

គេបាន $\ln f(x)=ax+b$ នាំឱ្យ $f(x)=e^{ax+b}$

ដូចនេះ $f(x)=e^{ax+b}$ ដែល $a,b\in IR$ ។

លំហាត់ទី១៨

គេឱ្យចតុកោណប៉ោង $\mathbf{ABCD}$ មួយមានជ្រុង$\mathbf{AB = a\,, BC = b\,,}$
$\mathbf{CD = c}$ និង $\mathbf{DA = d}$ ។

$\mathbf{P}$ ជាចំនុចមួយនៅក្នុងចតុកោណហើយ $\mathbf{K\,, L\,, M\,, N}$ ជាចំណោលកែង
នៃចំនុច $\mathbf{P}$ លើជ្រុង $\mathbf{[AB],[BC],[CD],[DA]}$ រៀងគ្នា ។

គេដឹងថា $\mathbf{\frac{PK}{AB} = \frac{PL}{BC} = \frac{PM}{CD} = \frac{PN}{DA} = h}$ ។

ក. ចូរស្រាយថា $\mathbf{h = \frac{2S}{a^2 + b^2 + c^2 + d^2}}$ ដែល $\mathbf{S}$ ជាផ្ទៃក្រឡានៃ
ចតុកោណ $\mathbf{ABCD}$ ។

ខ.ចូរបង្ហាញថា $\mathbf{h \le \frac{1}{2}}$

ដំណោះស្រាយ

ក.ស្រាយថា $\mathbf{h = \frac{2S}{a^2 + b^2 + c^2 + d^2}}$



គេមាន $\mathbf{S = S_{PAB} + S_{PBC} + S_{PCD} + S_{PDA}}$

$$\mathbf{= \frac{1}{2}a.PK + \frac{1}{2}b.PL + \frac{1}{2}c.PM + \frac{1}{2}d.PN}$$

ដោយ $\mathbf{\frac{PK}{AB} = \frac{PL}{BC} = \frac{PM}{CD} = \frac{PN}{DA} = h}$

គេទាញ $\mathbf{PK = ah\,, PL = bh\,, PM = ch\,, PN = dh}$

គេបាន $\mathbf{S = \frac{1}{2}a^2h + \frac{1}{2}b^2h + \frac{1}{2}c^2h + \frac{1}{2}d^2h}$

ដូចនេះ $\mathbf{h = \frac{2S}{a^2 + b^2 + c^2 + d^2}}$ ។

ខ.បង្ហាញថា $\mathbf{h \le \frac{1}{2}}$

គេមាន $\mathbf{S = S_{ABC} + S_{CDA} = \frac{1}{2}(ab\sin B + cd\sin D)}$

ដោយ $\mathbf{\sin B \le 1}$ និង $\mathbf{\sin D \le 1}$ នោះគេបាន :

$\mathbf{S \le \frac{1}{2}(ab + cd)}$ ដោយ $\mathbf{ab \le \frac{a^2 + b^2}{2}}$; $\mathbf{cd \le \frac{c^2 + d^2}{2}}$

គេបាន $\mathbf{S \le \frac{a^2 + b^2 + c^2 + d^2}{4}}$

តាមសម្រាយខាងលើ $\mathbf{h = \frac{2S}{a^2 + b^2 + c^2 + d^2}}$

ដូចនេះ $\mathbf{h \le \frac{2(\frac{a^2 + b^2 + c^2 + d^2}{4})}{a^2 + b^2 + c^2 + d^2} = \frac{1}{2}}$ ។

លំហាត់ទី១៩

គេឱ្យចតុកោណប៉ោង $ABCD$ មួយមានជ្រុង $AB = a$, $BC = b$ $CD = c$ និង $DA = d$ ។ O ជាចំនុចមួយនៅក្នុងចតុកោណនេះដែល $\angle OAB = \angle OBC = \angle OCD = \angle ODA = \theta$ ($0 < \theta < 90^o$)

ក. ចូរស្រាយថា $\tan\theta = \dfrac{4S}{a^2+b^2+c^2+d^2}$

ដែល S ជាផ្ទៃក្រឡានៃចតុកោណ $ABCD$ ។

ខ. កំនត់ θ ដោយដឹងថា $\tan\theta$ មានតម្លៃធំបំផុត ។

ដំណោះស្រាយ

ក. ស្រាយថា $\tan\theta = \dfrac{4S}{a^2+b^2+c^2+d^2}$



តាង $OA = x$, $OB = y$, $OC = z$, $OD = t$ ។

តាមទ្រឹស្តីបទកូស៊ីនូសក្នុង $\Delta OAB, \Delta OBC, \Delta OCD, \Delta ODA$:

$$y^2 = a^2 + x^2 - 2ax\cos\theta \quad (1)$$

$$z^2 = y^2 + b^2 - 2by\cos\theta \quad (2)$$

$$t^2 = z^2 + c^2 - 2zc\cos\theta \quad (3)$$

$$x^2 = t^2 + d^2 - 2td\cos\theta \quad (4)$$

បូកសមីការ $(1),(2),(3)\ \&\ (4)$ គេទាញបាន :

$$\cos\theta = \frac{a^2 + b^2 + c^2 + d^2}{2(ax + by + cz + dt)} \quad (5)$$

ម្យ៉ាងទៀត $S = S_{OAB} + S_{OBC} + S_{OCD} + S_{ODA}$

ឬ $S = \frac{1}{2}(ax + by + cz + dt)\sin\theta$

គេទាញ $\sin\theta = \frac{2S}{ax + by + cz + dt} \quad (6)$

ចែកទំនាក់ទំនង (6) និង (5) អង្គ និង អង្គគេបាន :

$$\tan\theta = \frac{4S}{a^2 + b^2 + c^2 + d^2}$$ ។

ខ. កំនត់ θ ដោយដឹងថា $\tan\theta$ មានតម្លៃធំបំផុត :

គេមាន $S = S_{ABC} + S_{CDA} = \frac{1}{2}(ab\sin B + cd\sin D)$

ដោយ $\sin B \le 1$ និង $\sin D \le 1$ នោះគេបាន :

$\mathbf{S \le \frac{1}{2}(ab + cd)}$ ដោយ $\mathbf{ab \le \frac{a^2 + b^2}{2}}$; $\mathbf{cd \le \frac{c^2 + d^2}{2}}$

គេបាន $\mathbf{S \le \frac{a^2 + b^2 + c^2 + d^2}{4}}$

ដោយ $\mathbf{\tan\theta = \frac{4S}{a^2 + b^2 + c^2 + d^2}}$

គេទាញ $\mathbf{\tan\theta \le \frac{4\left(\frac{a^2 + b^2 + c^2 + d^2}{4}\right)}{a^2 + b^2 + c^2 + d^2} = 1}$

ដូចនេះដើម្បីឱ្យ $\mathbf{\tan\theta}$ មានតម្លៃធំបំផុតលុះត្រាតែ $\mathbf{\theta = 45^o}$ ។

លំហាត់ទី២០

ចំពោះគ្រប់ $x;y\geq 0$ ចូរស្រាយបញ្ជាក់វិសមភាព :

$$\sqrt{x^2-x+1}\sqrt{y^2-y+1}+\sqrt{x^2+x+1}\sqrt{y^2+y+1}\geq 2(x+y)$$

(Kazakhstan NMO 2010)

ដំណោះស្រាយ

ស្រាយបញ្ជាក់វិសមភាព :

$$\sqrt{x^2-x+1}\sqrt{y^2-y+1}+\sqrt{x^2+x+1}\sqrt{y^2+y+1}\geq 2(x+y)$$



ជ្រើសរើសចតុកោណប៉ោង **ABCD** មួយមានអង្កត់ទ្រូង **AC** និង **BD** ប្រសព្វ

គ្នាត្រង់ចំនុច $\mathbf{I}$ ដែល $\mathbf{IA = x}$, $\mathbf{IC = y}$, $\mathbf{IB = ID = 1}$

និង $\angle \mathbf{AIB} = \angle \mathbf{CID} = \mathbf{60^o}$ ។ តាមទ្រឹស្តីបទកូស៊ីនូសគេបាន :

$$\mathbf{AB = \sqrt{x^2 - x + 1}} \ , \ \mathbf{CD = \sqrt{y^2 - y + 1}}$$
$$\mathbf{AD = \sqrt{x^2 + x + 1}} \ , \ \mathbf{BC = \sqrt{y^2 + y + 1}}$$

តាមទ្រឹស្តីបទអឺលែ $\mathbf{AC.BD \le AB.CD + AD.BC}$

